ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការចិញ្ចឹមបំប៉នគោ




រៀបចំដោយ **នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**

សហការជាមួយ **នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**

ឧបត្ថម្ភដោយ **គំរោងការផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី**

**រៀបរៀងដោយ:** **លោក ម៉ារី ម៉ាឃ្លីន** (Murray Maclean)

**កាលបរិច្ឆេទ: ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាង: គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

DRAFT

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមាន គោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបាន ឆ្លងការពិនិត្យពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋាន ជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករ ដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋា*ភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

DRAFT

## អារម្ភកថា

ពាក្យពេញនៃ បអប គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយ បញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័តិមានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរ បច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រ កម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការ ក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗ ទៀត ដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់ ។បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័តិមានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈ ប្រភព ជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងព័តិមានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័តិមានសំខាន់ៗ របស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បអប ផ្ទុកនូវបទ ពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មក អនុម័ត និងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

DRAFT

## មាតិកា


១-សេចក្តីអធិប្បាយ .................................... អែរ្រ1 ចប្បុកមារក ន្យុត បមេិនហេ។

២-ការណែនាំបច្ចេកទេស .................................... អែរ្រ1 ចប្បុកមារក ន្យុត បមេិនហេ។

២.១ សង្ខេបនៃការណែនាំបច្ចេកទេស .................................... ៣

២.២ ការកត់សំគាល់លើការណែនាំបច្ចេកទេស .................................... ៣

*២.២.១ ទិញគោដែលមានអាយុអាចពិឃាដបានក្នុងសភាពស្គម មានសុខភាពល្អ ស្លូត និង មានតម្លៃសមរម្យ .................................... ៣*

*២.២.២ ព្យាបាលគោជាមួយថ្នាំព្យាបាលប៉ារ៉ាស៊ីតដើម្បីសំលាប់ប៉ារ៉ាស៊ីតខាងក្នុងនិងខាងក្រៅ និងចាក់ថ្នាំគោនូវវ៉ាក់សាំងគ្រប់មុខ ..... ៤*

*២.២.៣ ផ្តល់ចំណីគោនូវល្បាយចំណីផ្សំ និងស្មៅខៀវ និង ទឹកស្អាត.................................... ៤*

*២.២.៤ ត្រួតពិនិត្យការកើន និង លក្ខខណ្ឌនៃទម្ងន់.................................... ១១*

*២.២.៥ ធ្វើការលក់គោនៅតម្លៃត្រឹមត្រូវ .................................... ១១*

២.៣ ផលចំណេញផ្នែកសេដ្ឋកិច្ច .................................... ១២

៣-ការណែនាំលើការងារផ្សព្វផ្សាយ .................................... អែរ្រ1 ចប្បុកមារក ន្យុត បមេិនហេ។

៣.១ ការរៀបចំស្ថាប័ន.................................... ១៥

៣.២ ការធ្វើផែនការសកម្មភាព .................................... ១៦

៣.៣ ឧបករណ៍ និង សំភារៈ.................................... ១៩

៣.៤ ថវិកាសម្រាប់ការធ្វើបង្ហាញ .................................... ១៩

៣.៥ ទីកន្លែងអនុវត្តគម្រោង .................................... ២១

៤. ឧបសម្ព័ន .................................... ២១

៤.១ ឧបសម្ព័ន្ធទី១. ការណែនាំលើទម្ងន់គោ.................................... ២១

៤.២ ឧបសម្ព័ន្ធទី២. ការណែនាំលើការផ្តល់ចំណីគោ.................................... ២២

៤.៣ ឧបសម្ព័ន្ធទី៣. ការណែនាំលើសមាសធាតុសាច់នៃគោក្នុងស្រុក .................................... ២៣

៤.៤ ឧបសម្ព័ន្ធទី៤. របាយការណ៍របស់កសិករគំរូ .................................... ២៤

៤.៥ ឧបសម្ព័ន្ធទី៥: សៀវភៅគំរូអ្នកគ្រប់គ្រងថ្នាក់ស្រុក .................................... ២៧


DRAFT

## ១-សេចក្តីអធិប្បាយ

ឈ្មោះ — ការចិញ្ចឹមបំប៉នគោ

ថ្ងៃ ខែ ឆ្នាំ — ខែ មករា ឆ្នាំ ២០០៦

ប្រភពបទដ្ឋានអនុវត្តបច្ចេកវិទ្យា — Murray Maclean

បច្ចេកវិទ្យា និង ដំណើរការផ្សព្វផ្សាយនេះត្រូវបានធ្វើសាកល្បងយ៉ាងច្រើន នៅប្រទេសវៀតណាមនៅក្រោមគំរោងការផ្លាស់ប្តូរវិស័យកសិកម្ម ២000-២00៥ និងត្រូវបានអនុវត្តសាកល្បងលើផងដែរក្នុងខេត្តពោធិសាត់ក្នុងឆ្នាំ ២00៥ ។

ទិសដៅ និង ផលប្រយោជន៍ — ធ្វើឱ្យប្រសើរនូវជីវភាពរបស់កសិករតាមរយៈការចិញ្ចឹមបំប៉នគោ សម្រាប់ពិឃាដដើម្បីបំរើទីផ្សារក្នុងស្រុក ។

បទដ្ឋានអនុវត្តបច្ចេកវិទ្យា គឺមានទិសដៅបន្ថែមតម្លៃថែមទៀតដល់គោមុនពេលពិឃាដ តាមរយៈការផ្តល់ចំណីបំប៉នដល់គោដើម្បីបង្កើនទម្ងន់ និងសាច់របស់វា។ កសិករអាចចំណេញប្រាក់ចំនួន ៦00.000រៀល លើរយៈពេល ២ខែ បន្ទាប់ពីទិញគោពូជក្នុងស្រុក ដែលមានសភាពស្គម១ចំនួន ២ក្បាល គឺកសិករគ្រាន់តែចំណាយថវិកាដំបូងក្នុងការទិញគោចំនួន ២.000.000រៀល និងផ្តល់ចំណីបំប៉នបន្ថែម។ បច្ចេកវិទ្យានេះ អាចត្រូវបានប្រើប្រាស់ដោយកសិករដែលលក់គោជា ចំនែកមួយនៃការគ្រប់គ្រងកសិដ្ឋាន ដូចជា នៅពេលគោមានអាយុចាស់ ឬគោ ថយចុះកំលាំងពលកម្ម ឬអស់សមត្ថភាពបន្តពូជ ឬដោយកសិករ និងឈ្មួញដែល អាចទិញគោ ជាពិសេសដែលមានគោលបំណងចិញ្ចឹមបំប៉នគោសម្រាប់ពិឃាដ ។

វាមានការបង្កើននូវទំនាក់ទំនង រវាងជំនាញបច្ចេកទេស និងផ្សព្វផ្សាយក្នុងចំណោមស្ថាប័នដែលពាក់ព័ន្ធ ដូចជា ភ្នាក់ងារពេទ្យសត្វភូមិ និងមន្ត្រីបច្ចេកទេស និងផ្សព្វផ្សាយ ។

លក្ខខណ្ឌសមស្របទៅនឹងបច្ចេកទេស — ការចូលទិន្នន័យសំខាន់១

- គោដែលមានអាយុអាចពិឃាដបាន
- ស្មៅគោ
- ពលកម្ម។ ដើម្បីចិញ្ចឹមបំប៉នគោ២ក្បាល ជាមធ្យមគឺត្រូវការពលកម្មដែលចំណាយរយៈពេល ៣ម៉ោងក្នុង១ថ្ងៃសម្រាប់រយៈពេល ២ខែ ដែលពេល

DRAFT

វេលានេះសម្រាប់ចំណាយនៅកន្លែងចិញ្ចឹមគោ និងកាត់ និងប្រមូលស្មៅ ឱ្យគោស៊ី។ ការណែនាំនេះអាចប្រែប្រួលយ៉ាងច្រើន គឺភាគច្រើនអាស្រ័យ ទៅលើទីតាំងស្មៅ និងទឹក និងមធ្យោបាយដឹកជញ្ជូន។ ប្រសិនបើស្មៅគោ ត្រូវបានទិញជាជាងកាត់ ឬប្រមូល ចំណាយពលកម្មនឹងមានការថយចុះ ប៉ុន្តែថវិកាត្រូវបានកើនឡើង។ កំលាំងពលកម្ម ត្រូវការថែមទៀត សម្រាប់ទិញ និងលក់គោ ដែលបញ្ហានេះនឹងមានខុសគ្នាច្រើនផងដែរ គឺអាស្រ័យទៅលើការរៀបចំក្នុងការលក់ដូរនៅទីកន្លែងនោះ។

- ចំណីផ្សំ (ដូចជា សណ្តែកសៀង ម្សៅពោត ម្សៅដំឡូងមី ចុងអង្ករ កន្ទក់ អំបិល អ៊ុយរ៉េ អាហារបន្ថែមកាល់ស្យូមឬហ្វូស្វរ និងវីតាមីនគ្រប់មុខ)។ វាមានជម្រើសជាច្រើនដើម្បីជ្រើសរើសប្រភេទចំណីផ្សំ ។ ដូច្នេះចំណីផ្សំ អាចត្រូវបានសំរបសំរួលទៅតាមតម្លៃទីផ្សារក្នុងស្រុក និងភាពរកបាន នូវសមាសធាតុផ្សំផ្សេងៗ។
    - ថ្នាំព្យាបាលប៉ារ៉ាស៊ីតដល់គោនៅដំណាក់កាលដំបូងនៃរយៈពេលចិញ្ចឹមបំប៉ន។

ការចូលដល់ទីផ្សារសម្រាប់គោដែលចិញ្ចឹមបំប៉នៈ

"បទដ្ឋានអនុវត្តបច្ចេកវិទ្យា" គឺត្រូវបានអនុវត្តទៅលើតែកសិករមានជីវភាពធូធារ ឬឈ្មួញទិញ-លក់គោដែលមានធនធានគ្រប់គ្រាន់សម្រាប់ទិញ និងចិញ្ចឹមបំប៉នគោ។ ទោះបីជាយ៉ាងណាក៏ដោយ បទដ្ឋាននេះអាចត្រូវបាន អនុវត្តផងដែរលើកសិករដែលលក់គោដើម្បីពិឃាដ។

កសិករត្រូវការថវិកាប្រហែល ២.០០០.០០០រៀលដើម្បីទិញគោ និងចិញ្ចឹមបំប៉នគោពូជក្នុងស្រុកចំនួន ២ក្បាល។ ប្រសិនបើកសិករមានគោ ហើយពួកគេត្រូវការប្រហែល ៤៥០.០០០រៀល ដើម្បីទិញចំណីផ្សំ និងថ្នាំសម្រាប់ ចិញ្ចឹមបំប៉នគោចំនួន ២ក្បាល។ ថវិកាចំណាយនេះនឹងមានការប្រែប្រួលគឺអាស្រ័យ ទៅលើទំហំនិងតម្លៃរបស់គោ។

កសិករដែលមានគោរួចហើយ ត្រូវការថវិកាប្រហែល ២២៥.០០០រៀល ដើម្បីទិញថ្នាំ និងចំណីសម្រាប់ចិញ្ចឹមបំប៉នគោមួយក្បាល។

DRAFT

## ២-ការណែនាំបច្ចេកទេស

### ២.១ សង្ខេបនៃការណែនាំបច្ចេកទេស

ក. ទិញគោដែលមានអាយុអាចពិឃាដបានក្នុងសភាពស្គម មានសុខភាពល្អ ស្លូត និងមានតម្លៃសមរម្យ ។

ខ. ព្យាបាលគោជាមួយថ្នាំព្យាបាលប៉ារាស៊ីតដើម្បីសំលាប់ប៉ារាស៊ីតខាងក្នុងនិងខាងក្រៅនិងចាក់ថ្នាំគោនូវវីតាមីនគ្រប់មុខ

គ. ផ្តល់ចំណីគោនូវល្បាយចំណីផ្សំ និងស្មៅខ្សែវ និងទឹកស្អាត ។

ឃ. ត្រួតពិនិត្យការកើន និងលក្ខខណ្ឌនៃទម្ងន់ ។

ង. ធ្វើការលក់គោនៅតម្លៃត្រឹមត្រូវ ។

### ២.២ ការកត់សំគាល់លើការណែនាំបច្ចេកទេស

#### ២.២.១ ទិញគោដែលមានអាយុអាចពិឃាដបានក្នុងសភាពស្គម មានសុខភាពល្អ ស្លូត និង មានតម្លៃសមរម្យ

*សារៈតា*

គោភាគច្រើនក្នុងប្រទេសកម្ពុជាដែលបានពិឃាដ គឺមានសភាពស្គម ។ បញ្ហានេះគឺបណ្តាលមកពីៈ

- គោដែលសម្រាប់បង្កាត់ និងបំរើការងារជាញឹកញាប់ត្រូវបានថែទាំដោយកសិករ គឺនៅពេលដែលគោទាំងនោះ មានអាយុចាស់វានៅសភាពស្គមដដែល ។
- កសិករជាញឹកញាប់លក់គោក្នុងក្រោយរដូវប្រាំងយូរដែលក្នុងពេលនេះស្មៅពុំមានគ្រប់គ្រាន់និង គោមានសភាពស្គម ។
- ខ្វះខាតប្រព័ន្ធចិញ្ចឹមបំប៉នដល់គោ និងជំនាញ ចំណេះដឹង និងការបញ្ចូលបច្ចេកវិទ្យាផ្សេងៗទៀតដែលត្រូវការសម្រាប់បង្កើតប្រព័ន្ធចិញ្ចឹមនេះ ។

ការចិញ្ចឹមបំប៉នគោបច្ចុប្បន្ននេះ គឺមានលក្ខណៈខ្នាតតូចដែលចិញ្ចឹមឱ្យស៊ីស្មៅក្នុងតំបន់ក្បែរទីសត្តឃាដ ។

ការពិឃាដ ឬ នាំចេញគោដែលមានសភាពស្គម គឺជាការខាតបង់ណាស់ក្នុងផ្នែកសេដ្ឋកិច្ច ពីព្រោះគោទាំងនេះអាច ត្រូវបានចិញ្ចឹមបំប៉នបានគឺអាចចំនេញបានថវិកាច្រើនមុនពេលពិឃាដ ។

DRAFT

## ប្រភេទគោត្រូវទិញ

គោដែលទិញសម្រាប់ចិញ្ចឹមបំប៉នគួរ ឋិតនៅក្រោមលក្ខខណ្ឌនៅពេលលក់អតិបរិមា។ នៅក្នុងប្រទេសកម្ពុជាកសិករ ជាធម្មតាចិញ្ចឹមគោមានសភាពស្គម  ស្គមល្មម និងខ្លាញ់ច្រើន។ អាស្រ័យហេតុនេះ កសិករអាចទិញគោដែលស្ថិតក្នុងសភាព ស្គម ឬ ស្គមល្មម ហើយដែលធ្វើឱ្យទទួលផលចំណេញយ៉ាងច្រើន។

គោឈ្មោល  គោឈ្មោលក្រៀវ  ឬគោញីអាចត្រូវបានទិញ។  គោដែលអត់ធ្មេញមិនគួរទិញឡើយ។  ពូជគោគ្រប់ប្រភេទ អាចទិញបាន។ គោគួរមានសុខភាពល្អ។ គោដែលមានសុខភាពល្អ គឺមានភ្នែកភ្លឺ និងពូកែស៊ីចំណី។

គោនៅគ្រប់អាយុអាចត្រូវបានទិញសម្រាប់ចិញ្ចឹមបំប៉ន  ប៉ុន្តែគោដែលមានអាយុក្មេងជាទូទៅមានតម្លៃថ្លៃណាស់ សម្រាប់ ចិញ្ចឹមបំប៉នដើម្បីយកទៅពិឃាដ ពីព្រោះតម្លៃរបស់វាសម្រាប់បង្កាត់នឹងខ្ពស់ជាងតម្លៃសាច់របស់វា។

គោដែលមានអារម្មណ៍ឆាប់ភ័យស្លន់ស្លោមិនគួរទិញឡើយ  ពីព្រោះពួកគេអាចមានស្រ្តេសនៅពេលដែលកសិករចិញ្ចឹម វា។ ជាលទ្ធផល គោនឹងមានការថយចុះការស៊ីចំណីនិងមានការលូតលាស់ថយចុះ។ គោដែលមានអារម្មណ៍ឆាប់ភ័យនឹងមិន មាន អារម្មណ៍សំរាកនៅពេលមានវត្តមានមនុស្ស។

ជាទូទៅ មេគោដែលផើមអាយុ ៥ខែ ឡើងទៅ មិនគួរទិញមកចិញ្ចឹមបំប៉នដើម្បីពិឃាដ។




*មេគោពេញវ័យក្នុងលក្ខខណ្ឌស្គមត្រៀមសម្រាប់ពិឃាដ។ មេគោនេះមានលក្ខណៈល្អសម្រាប់ផ្ដល់ចំណី និង ចិញ្ចឹមបំប៉ន*




*គោឈ្មោលក្រៀវពេញវ័យក្នុងលក្ខខណ្ឌស្គមល្មមបែបនេះគួរត្រូវបានទិញសម្រាប់ផ្ដល់ចំណីនិងចិញ្ចឹមបំប៉ន។*

### *ទិញគោក្នុងតម្លៃសមរម្យ*

ដើម្បីចិញ្ចឹមបំប៉នគោសម្រាប់ពិឃាដឱ្យបានផលចំណេញច្រើន កសិករគួរគិតពីតម្លៃសាច់សត្វគោតែមួយគត់ ។

ដើម្បីទិញគោដែលមានសភាពស្គមក្នុងតម្លៃសមរម្យ កសិករត្រូវវាយតម្លៃសមាសធាតុសាច់ ។ ជាញឹកញាប់ វាមិន ងាយស្រួលឡើយសម្រាប់កសិករដែលពុំមានបទពិសោធន៏ ។ អ្នកទិញគោដែលមានបទពិសោធន៍អាចវាយតម្លៃយ៉ាងសុក្រិត្យ នូវ ចំនួនសាច់នៅលើសត្វគោ ប៉ុន្តែពេលខ្លះពួកគេអាចមានកំហុសដែរ ។

**កសិករអាចធ្វើការកែលំអលើជំនាញនៃការវាយតម្លៃសមាសធាតុសាច់ដោយ**

- ជាលើកដំបូង ធ្វើការវាយតម្លៃទម្ងន់គោស្រស់តាមរយៈការប្រើប្រាស់ម៉ែត្រខ្សែ ។
- ជាលើកទី២ ធ្វើការវាយតម្លៃភាគរយសាច់នៃសត្វ ។
- ជាលើកទី៣ ប្រើប្រាស់ព័ត៌មាននេះដើម្បីវាយតម្លៃចំនួនសាច់សរុប ។

បន្ទាប់មក កសិករវាយតម្លៃនៃសត្វដោយយកចំនួនសាច់សរុប គុណនឹងតម្លៃសាច់នៅតាមទីផ្សារបច្ចុប្បន្ន (តម្លៃ សាច់គោនៅភ្លៅខាងក្រោយ) ។

**ដើម្បីវាយតម្លៃទម្ងន់ស្រស់របស់គោ**

- ប្រវែងនៅជុំវិញទទឹងខ្លួនគោ និង ប្រវែងពីចំណុចស្មារហូតដល់ឆ្អឹងគូថគួរត្រូវបានវាស់ ។
- បន្ទាប់មក រូបមន្តខាងក្រោមត្រូវបានប្រើប្រាស់

$$\text{ទម្ងន់គោ (គ.ក្រ)} = \text{ទទឹង (ម)} \times \text{ទទឹង (ម)} \times \text{បណ្តោយ (ម)} \times ៩0$$

**តារាងវាយតម្លៃទម្ងន់គោត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ**



*ទម្ងន់គោ អាចត្រូវបានវាយតម្លៃ ដោយវាស់ប្រវែងទទឹងនិងបណ្តោយរបស់គោ ពីស្មារហូតដល់ឆ្អឹងគូថ និងប្រើប្រាស់រូបមន្តខាងលើ ។ នេះជាការណែនាំទូ ទៅតែមួយគត់ ប៉ុន្តែជាចំណុចចាប់ផ្តើមដែលមានប្រយោជន៍សម្រាប់កសិករដឹងអំពីទម្ងន់គោ ។*

សមាសធាតុសាច់របស់គោអាស្រ័យទៅលើលក្ខខណ្ឌ (ស្គម ស្គមល្មម ឬធាត់)និងការកំណត់សាច់ដុំ(ប្រភេទទី១, ២ ឬ ៣)

លក្ខខណ្ឌនេះ គឺជាមុខងារនៃចំណីអាហារ និងសាច់ដុំសំខាន់ដែលជាមុខងារនៃពូជ និងភេទ។ ការបែងចែករវាង លក្ខខណ្ឌ និងការកំណត់សាច់ដុំនេះ គឺទាមទានូវបទពិសោធន៍ខ្លះ។

**ក្រាហ្វិកទី១. ការណែនាំលើប្រភេទសាច់ដុំរបស់គោ**

**Guide to Muscles Types in cattle**



**Muscle Type 1** **Muscle Type 2** **Muscle Type 3**

គោឈ្មោលដែលមិនក្រៀវ មានសាច់ដុំច្រើនជាងគោឈ្មោលដែលក្រៀវ ចំណែកគោញីមានសាច់ដុំតិច។ វាមានពូជ គោចំនួន ៣ ប្រភេទសំខាន់ៗនៅក្នុងប្រទេសកម្ពុជារួមមាន:

- ពូជគោតូចៗក្នុងស្រុក ឬ ពូជគោមានពណ៌ក្រហម ឬ លឿង ដែលជាធម្មតាគេឃើញនៅក្នុងតំបន់វាលស្រែ។
- ពូជគោ ហារ៉្យាណាដែលមានពណ៌ស កំពស់ខ្ពស់ ដែលជាធម្មតាសង្កេតឃើញនៅក្នុងតំបន់ជាប់មាត់ទន្លេ។
- ពូជគោកូនកាត់រវាងពូជគោហារ៉្យាណា និង ពូជគោក្នុងស្រុក។

វាមានពូជគោប្រាម៉ាន់ដែលមានសាច់ដុំធំ និង ពូជកូនកាត់របស់វា។ ប៉ុន្តែ ពូជគោទាំងនេះមានចំនួនតិចតួចណាស់នៅក្នុងប្រទេសកម្ពុជា។

រវាងពូជទាំងនេះសាច់ដុំមានភាពខុសគ្នាយ៉ាងខ្លាំង ។ ការស្រាវជ្រាវការខុសគ្នានេះមានការខ្វះខាតនៅក្នុងប្រទេស កម្ពុជា ដែលជាហេតុធ្វើឱ្យចំណេះដឹងបច្ចុប្បន្នក្នុងផ្នែកនេះមានកំរិត។

គោពូជក្នុងស្រុកជាទូទៅមានសាច់ដុំកំរិតទី១ ទោះបីជាមានកំរិតសាច់ដុំឈានដល់កំរិតទី២សម្រាប់គោឈ្មោលយ៉ាងណាក៏ដោយ។ ប្រភេទពូជគោហារ៉្យាណាដែលមានពណ៌ស និងខ្ពស់ ហាក់បីដូចជាមានសាច់ដុំច្រើនជាងពូជគោក្នុងស្រុកដែល មានពណ៌ក្រហម គឺមានសាច់ដុំឈានដល់កំរិតទី២។ វាមានគោចំនួនតិចតួចណាស់ដែលមានសាច់ដុំកំរិតទី៣។

DRAFT



*គោដែលក្រៀវមានសាច់ដុំមិនល្អ គឺ សាច់ដុំកំរិតទី ១*



*ពូជគោហារ៉្យាណាពេញវ័យញី មានសាច់ដុំល្អ គឺ សាច់ដុំកំរិតទី ២*

## តារាងទី១. ការណែនាំលើសមាសធាតុសាច់តាមរយៈប្រភេទ និង លក្ខខណ្ឌសាច់ដុំ

| ការណែនាំលើសមាសធាតុសាច់តាមរយៈប្រភេទ និង លក្ខខណ្ឌសាច់ដុំ | | | |
|---|---|---|---|
| | សាច់ដុំកំរិតទី១ | សាច់ដុំកំរិតទី២ | សាច់ដុំកំរិតទី៣ |
| ស្គម | ២២% | ២៥% | ៣២% |
| ល្មម | ២៧% | ៣២% | ៣៧% |
| ធាត់ | ៣២% | ៣៧% | ៤២% |

វាមានសារៈសំខាន់ណាស់ដែលអាចបំបែកខ្លាញ់ចេញពីសាច់ដុំ។ ខ្លាញ់ វាបង្កនូវដុំមូល និងមានភាពញ័រនៅ ពេលដែលគោធ្វើចលនា។ សាច់ដុំមានភាពសំប៉ែត និង រឹងមាំ។

**ក្រាហ្វិកខាងក្រោមមានបង្ហាញ គំរូនៃការគណនាតម្លៃរបស់គោនៅទីកន្លែងចិញ្ចឹម។**

## ក្រាហ្វិកទី២. គំរូនៃការគណនាតម្លៃរបស់គោ

| គំរូនៃការគណនាតម្លៃរបស់គោ | |
|---|---|
| ពូជជ | ក្នុងស្រុក |
| ភេទ | ញី |
| អាយុ (ឆ្នាំ) | ៨ |
| លក្ខខណ្ឌ | មធ្យម |
| ប្រភេទសាច់ដុំ (១-៣) | ១ |
| ទម្ងន់ (គ.ក្រ) | ១៨០ |
| សមាសធាតុសាច់ (%) | ២៧ |
| សមាសធាតុសាច់ (គ.ក្រ) | ៤៩ |

DRAFT

| | |
|---|---|
| តម្លៃសាច់ (គ.ក្រ ក្នុង ថ្ងៃ) | ១៥.០០០ |
| តម្លៃសត្វ (រៀល) | ៧២៩.០០០ |

ទាក់ទិននឹងសកម្មភាពលក់ដូរ តម្លៃនឹងអាស្រ័យទៅនឹងកត្តាជាច្រើនដូចជាការតថ្លៃជាដើម។ តម្លៃនៃការស្រាវជ្រាវ សំរុះសំរួល និងដឹកជញ្ជូន ក៏មានសារៈសំខាន់ផងដែរ។ អ្នកទិញគោ គួរព្យាយាមគិតគូរពិចារណាអំពីស្ថានភាពទីផ្សារឱ្យបានច្បាស់លាស់ និងព្យាយាមកាត់បន្ថយតម្លៃនៃការស្រាវជ្រាវ សំរុះសំរួល និងដឹកជញ្ជូនឱ្យដល់កំរិតអប្បបរមា។

## ២.២.២ ព្យាបាលគោជាមួយថ្នាំព្យាបាលប៉ារាស៊ីតដើម្បីសំលាប់ប៉ារាស៊ីតខាងក្នុងនិងខាងក្រៅ និងចាក់ថ្នាំគោនូវវីតាមីនគ្រប់មុខ

គោនៅប្រទេសកម្ពុជា អាចឆ្លងប៉ារាស៊ីតខាងក្នុងជាច្រើនប្រភេទ (ឧទាហរណ៏ ព្រូនមូល ព្រូនសំប៉ែត្រ) និងប៉ារាស៊ីតខាងក្រៅ (ចៃ ទីកកែ រុយ)។ ក្នុងខណៈដែលគោទាំងអស់មិនអាចឆ្លងប៉ារាស៊ីតទាំងនេះ គោដែលត្រូវយកមកចិញ្ចឹមបំប៉ន គួរត្រូវបានព្យាបាលដើម្បីប្រាកដថាអត់មានឆ្លងប៉ារាស៊ីតទាំងនេះ។

ថ្នាំដែលមានប្រសិទ្ធភាពបំផុតសម្រាប់ការប្រើប្រាស់គឺ អ៊ីវឺម៉ិចទីនបួស់។ ថ្នាំនេះសំលាប់ប៉ារាស៊ីត រួមមានព្រូនសំប៉ែតដែលរស់នៅក្នុងថ្លើម។ ថ្នាំនេះអាចត្រូវបានចាក់នៅក្រោមស្បែក។

គោគួរចាក់នូវវីតាមីនគ្រប់មុខផងដែរក្នុងពេលតែមួយនឹងការចាក់អ៊ីវឺម៉ិចទីន ដើម្បីធានាថាគោមានវីតាមីនគ្រប់គ្រាន់ដែលអាចជួយបង្កើនការស៊ីចំណីរបស់វា។

## ២.២.៣ ផ្តល់ចំណីគោនូវល្បាយចំណីផ្សំ និងស្មៅខៀវ និង ទឹកស្អាត

ទិសដៅនៃការផ្តល់ចំណីគឺបង្កើនទម្ងន់គោឱ្យបានឆាប់ ហើយការកើនទម្ងន់នោះជាសំខាន់មានសាច់ដុំ (សាច់) ដែលមានតម្លៃខ្ពស់ជាជាងមានខ្លាញ់ដែលមានតម្លៃទាប។

គោក៏អាចផ្តល់ចំណីស្មៅបៃតងដែលមានគុណភាពខ្ពស់ផងដែរ ប៉ុន្តែអត្រាធំធាត់នឹងប្រហែលជាមានកំរិតគឺ៤០០ក្រាមក្នុង១ថ្ងៃ។ នេះមានន័យថា ការចិញ្ចឹមបំប៉នគោស្គមពូជក្នុងស្រុកសម្រាប់ពិឃាដនិងចំណាយពេលប្រហែល ១០០ថ្ងៃ គឺសន្មត់ថាការកើនទម្ងន់ប្រហែល ៤០គ.ក្រ ពីការចិញ្ចឹមគោដែលមានលក្ខខណ្ឌស្គមឱ្យទៅជាធាត់។

គោផ្តល់ចំណីស្មៅបៃតងដែលមានគុណភាពខ្ពស់ និងចំណីផ្សំដែលមានភាពលាយខ្ពស់ក្នុងផ្នែកជាតិប្រូតេអ៊ីន និងថាមពល នឹងធ្វើឱ្យគោឆាប់រីកលូតលាស់គឺរហូតដល់ ៨០០ក្រាម ក្នុង១ថ្ងៃ។

នេះមានន័យថាការចិញ្ចឹមបំប៉នគោពូជក្នុងស្រុកដែលមានសភាពស្គមសម្រាប់ពិឃាដ នឹងចំណេញ ៥០ថ្ងៃ ដែលសន្មត់ ថាការកើនទម្ងន់ប្រហែល ៤០គ.ក្រ ពីការចិញ្ចឹមគោដែលមានលក្ខណៈស្គមឱ្យទៅជាធាត់។

អត្រាលូតលាស់ពិតប្រាកដនឹងមានការប្រែប្រួលយ៉ាងច្រើនដែលអាស្រ័យទៅនឹងពូជ លក្ខខណ្ឌ កំរិតសាច់ដុំ ភាពកាច ឬស្លូតរបស់គោ និងការគ្រប់គ្រងទូទៅ។

DRAFT

ទោះបីជាភាពចំណេញនៃប្រព័ន្ធទាំងពីនេះអាស្រ័យទៅនឹងតម្លៃនៃចំណី តម្រូវការពលកម្ម តម្លៃការប្រាក់ និងប្រព័ន្ធ ទីផ្សារយ៉ាងណាក៏ដោយ ក្នុងករណីជាច្រើនការផ្តល់ចំណីលាយនូវស្មៅបៃតង និងចំណីផ្សំក៏នៅតែផ្តល់ផលចំណេញ ។

វាមានស្មៅ និងវាលស្មៅមួយចំនួននៅប្រទេសកម្ពុជាដែលភាគច្រើនចំណីពណ៌បៃតង គឺជាវាលស្មៅធម្មជាតិ ។ ប្រភេទចំណីផ្សំផ្សេងៗគ្នាអាចត្រូវបានផ្តល់ចំណីទៅឱ្យគោសម្រាប់ចិញ្ចឹមបំប៉ន ។គំរូខ្លះត្រូវបានបង្ហាញក្នុងតារាងខាងក្រោមៈ

**តារាងទី២. ជម្រើសចំណីផ្សំសម្រាប់ការចិញ្ចឹមបំប៉នគោ**

| ជម្រើសចំណីផ្សំ | | | | | | |
|---|---|---|---|---|---|---|
| ធាតុផ្សំ | ចំណីផ្សំ | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ម្សៅត្រី ឬ សណ្តែកសៀង | ០ | ០ | ១០ | ៥ | ០ | ៥ |
| ពោត | ៥០ | ៧៥ | ០ | ២៥ | ៥០ | ២០ |
| កន្ទក់ | ៥០ | ២៥ | ០ | ០ | ០ | ០ |
| ម្សៅដំឡូងមី | ០ | ០ | ៩០ | ៦៥ | ៥០ | ៧០ |
| អ៊ុយរ៉េ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| អំបិល | ១ | ១ | ១ | ១ | ១ | ១ |
| ឧទាហរណ៍ៈ នៅក្នុងជម្រើសចំណីផ្សំទី ២ៈ ៧៥ផ្នែកនៃពោតគួរលាយជាមួយនឹង២៥ផ្នែកនៃកន្ទក់ និង ៣ផ្នែកនៃអ៊ុយរ៉េ និង ១ផ្នែកនៃអំបិល ។ ប្រសិនបើចំណីផ្សំដែលគ្មានម្សៅត្រីត្រូវបានផ្តល់ ការបន្ថែមកាល់ស្យូមឬហ្វូស្វ័រគួរធ្វើឡើងដើម្បី ធ្វើឱ្យគោមានការរីកលូតលាស់ ។ ម្សៅវីតាមីនគ្រប់មុខ ឬរ៉ែ គួរត្រូវបានបន្ថែមទៅក្នុងចំណីផ្សំ ។ | | | | | | |

**ដើម្បីស្របទៅនឹងធាតុផ្សំទាំងនេះ**

- ម្សៅត្រីនិងសណ្តែកសៀងគឺជាប្រភពប្រូតេអ៊ីនខ្ពស់ ។ ម្សៅត្រីមានអត្ថប្រយោជន៍ជាងគេ ព្រោះវាសំបូរជាតិ កាល់ស្យូមនិងហ្វូស្វ័រ ។
- ពោត និងកន្ទក់ គឺជាប្រភពថាមពលដែលមានប្រូតេអ៊ីនមធ្យម ។
- ម្សៅដំឡូងមី គឺជាប្រភពថាមពលដែលមានប្រូតេអ៊ីនតិចតួច ។
- អ៊ុយរ៉េ គឺជាប្រភពអាហារូតដែលអាចប្រើប្រាស់សម្រាប់ការផលិតប្រូតេអ៊ីននៅក្នុងសត្វ ។

DRAFT

• អំបិល បង្កើនការស៊ីចំណី និងជីវជាតិចំណី និងជាធាតុមានប្រយោជន៍សម្រាប់ការលូតលាស់របស់ សារពាង្គកាយ ។

អ៊ុយរ៉េដែលបានប្រើប្រាស់នៅក្នុងចំណីផ្សំនេះ គឺដូចគ្នាទៅនឹងអ៊ុយរ៉េដែលប្រើប្រាស់នៅក្នុងជី។ ប្រសិនបើគោស៊ីអ៊ុយរ៉េបរិមាណច្រើន គឺអាចស្លាប់បានដោយសារការពុល ។ អាស្រ័យហេតុនេះ បរិមាណអ៊ុយរ៉េមិនគួរលើសពីចំនួនដែលបានបង្ហាញ នៅក្នុងចំណីផ្សំនេះទេ ។ កសិករត្រូវប្រាកដថា គោមិនអាចស៊ីអ៊ុយរ៉េតែមួយមុខបានទេ ។

សមាសធាតុផ្សំផ្សេងៗរបស់ចំណីផ្សំនេះ គួរត្រូវបានលាយឱ្យបានល្អមុនពេលផ្តល់ចំណីឱ្យគោ។ ជាពិសេស អ៊ុយរ៉េ ត្រូវលាយឱ្យបានសព្វជាមួយចំណី ។



សមាសធាតុសម្រាប់ចំណីផ្សំ គួរត្រូវបានថ្លឹង មុនពេលលាយ ។
ចំណីផ្សំគួរថ្លឹងមុនពេល ផ្តល់ទៅឱ្យគោស៊ី ។



ស្មៅបៃតងអាចប្រមូល ឬ ទិញ ។

តម្លៃ និងភាពរកបាននៃសមាសធាតុនៃចំណីផ្សំ មានការប្រែប្រួលទៅតាមទីតាំង និងប្រព័ន្ធកសិកម្មនៃប្រទេសកម្ពុជា។ ប្រសិទ្ធភាពចំណីនៃចំណីផ្សំដែលមិនរួមបញ្ចូលម្សៅត្រី នឹងមិនត្រូវបានកើនឡើងតាមរយៈការប្រើប្រាស់នូវការបន្ថែម ជាតិកាល់ស្យូម និង ហ្វូស្វ័រ។ បច្ចុប្បន្នជាតិទាំងនេះអាចរកបាន ហើយដែលមានប្រភពពីប្រទេសថៃ និងវៀតណាម។ កន្លែង ដែលអាចរកបាន ការប្រើប្រាស់នូវជីវជាតិនេះ គឺអាស្រ័យទៅនឹងការណែនាំ។

ចំនួនសរុបនៃចំណីផ្សំ (ចំណីបៃតងនិងចំណីផ្សំ) ដែលបានផ្តល់សម្រាប់ចិញ្ចឹមបំប៉នគោ មានការខុសគ្នាអាស្រ័យទៅ នឹងទម្ងន់របស់វា។ ជាទូទៅ គោដែលចិញ្ចឹមបំប៉នអាចស៊ីចំណីក្នុងទម្រង់ម៉ាសស្ងួត ដោយគិតជាមធ្យមប្រមាណ ២.៥-៣% នៃទម្ងន់គោ។ សម្រាប់ការអនុវត្តន៍ យើងអាចសន្មត់ថា ចំណីបៃតងស្រស់ចំនួន ២០%នៃម៉ាស់ស្ងួត និងចំណីផ្សំ ៩០%នៃ ម៉ាស់ស្ងួត។ អាស្រ័យហេតុនេះ សត្វគោទម្ងន់ ២០០គ.ក្រ អាចស៊ីចំណីបៃតងស្រស់ប្រហែល ៣០គ.ក្រ ក្នុង១ថ្ងៃ។

ការណែនាំជាទូទៅសម្រាប់ការចិញ្ចឹមបំប៉នគោ គឺត្រូវផ្តល់ចំណីឱ្យបានច្រើនតាមដែលគោស៊ីអាចស៊ីបាន។ ទោះបីជាយ៉ាងណាក៏ដោយ ចំណីផ្សំមិនគួរឱ្យច្រើនលើសពីប្រហែល ៧០% នៃចំណី។ នេះមានន័យថា ចំនួនចំណីផ្សំសរុបក្នុង១ថ្ងៃ គួរ មាន ១,៥-២% នៃទម្ងន់របស់គោ។

DRAFT

នៅពេលដំបូង គោគួរផ្តល់ចំណីស្មៅបៃតងទាំងអស់ ប៉ុន្តែចំណីផ្សំត្រូវផ្តល់បន្តិចម្តងៗក្នុងរយៈពេល ៧-១០ថ្ងៃ។ ការធ្វើរបៀបនេះ គឺដើម្បីជៀសវៀងកុំឱ្យប្រព័ន្ធរំលាយអាហាររបស់គោមានការប៉ះពាល់ដោយសារតែការបង្កើនចំណីផ្សំលឿន ពេក និងដើម្បីកាត់បន្ថយចំណីដែលសេសសល់ដោយសារតែគោមិនទាន់សំរបទៅនឹងចំណីផ្សំនោះ។ តាមការណែនាំ គោអាច ផ្តល់ចំណីដែលមានចំនួន 0,៥ % នៃទម្ងន់គោ (ឧទាហរណ៍ៈ ១គ.ក្រ សម្រាប់គោដែលមានទម្ងន់ ២០០ គ.ក្រ) នៅថ្ងៃទី២ នៃ ការចិញ្ចឹមបំប៉ន ហើយចំនួននេះអាចបង្កើនជាប្រចាំរហូតដល់ ១,៥-២% នៃទម្ងន់គោ (៣-៤ គ.ក្រ សម្រាប់គោដែលមាន ទម្ងន់ ២០០គ.ក្រ ) លើរយៈពេល ៧-១០គ.ក្រ។ ការណែនាំលើការផ្តល់ចំណី ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ។

នៅក្នុងការអនុវត្តន៍ វាមានការប្រែប្រួលយ៉ាងច្រើនរវាងគោដែលស្ថិតក្នុងអត្រាមួយ ដែលគោទាំងនោះសំរបទៅនឹងចំណីផ្សំ ហើយអ្នកចិញ្ចឹមតម្រូវពិនិត្យមើលឱ្យបានម៉ត់ចត់លើគោក្នុងរយៈពេលនេះ។ ពេលខ្លះការបន្ថែមទឹកទៅនឹងចំណីផ្សំ នឹងបង្កើនការស៊ីចំណីផ្សំរបស់គោ។ ពេលខ្លះការលាយចំណីផ្សំជាមួយចំណីបៃតងអាចជួយជំរុញការស៊ីចំណីផ្សំ។ ឧបករណ៍ធ្វើពីដែក ឬប្លាស្ទិក ដូចនឹងឧបករណ៍ដែលបានប្រើប្រាស់សម្រាប់លាងចានក្នុងផ្ទះបាយ អាចប្រើប្រាស់ជាស្នូកសម្រាប់ដាក់ចំណីផ្សំ។

គោគួរផ្តល់ទឹកស្អាតជានិច្ច នៅក្នុងស្នូកដែលធ្វើពីដែក ឬប្លាស្ទិក។

គោដែលចិញ្ចឹមតែមួយក្បាល អាចស៊ីចំណីស្មៅបៃតង និងចំណីផ្សំដោយខ្លួនឯង ដែលជាហេតុធ្វើឱ្យកសិករអាចត្រួតពិនិត្យយ៉ាងជិតដល់លើការរីកចំរើនរបស់គោមួយៗ និងអាចឃើញប្រសិនបើមានបញ្ហាក្នុងការស៊ីចំណី។

### ២.២.៤ ត្រួតពិនិត្យការកើន និង លក្ខខណ្ឌនៃទម្ងន់

កសិករគួរត្រួតពិនិត្យទម្ងន់សត្វនិមួយៗរៀងរាល់អាទិត្យ ដោយប្រើប្រាស់ម៉ែត្រខ្សែ និងរូបមន្ត ប៉ុន្តែសារៈសំខាន់ផងដែរតាមការវាយតម្លៃតាមភ្នែក។

បន្ទាប់រយៈពេល ២អាទិត្យ ការវាយតម្លៃតាមភ្នែកគួរអាចធ្វើឡើង។ ការវាយតម្លៃតាមភ្នែកអាចសង្កេតជាតំបូង តាមរយៈការមើលនូវលក្ខខណ្ឌស្បែក និងរោម។ រោមរបស់គោគួរក្លាយជាភ្លឺរលោង។ ប្រសិនបើលក្ខខណ្ឌទាំងនេះមិនបាន ឃើញទេ កសិករគួរពិចារណាលក់គោក្នុងពេលដែលគោនោះមិនអាចចិញ្ចឹមបំប៉នបានឡើយ។

### ២.២.៥ ធ្វើការលក់គោនៅតម្លៃត្រឹមត្រូវ

កសិករគួរត្រួតពិនិត្យថា គោកំពុងបន្តកើនសាច់ដុំ គឺមិនកើនខ្លាញ់។ ប្រសិនបើសត្វកំពុងកើនខ្លាញ់ ពេលនោះគឺជាពេលដែលត្រូវលក់គោព្រោះខ្លាញ់គោពុំមានសូវមានតម្លៃដូចខ្លាញ់ជ្រូកឡើយ។

តាមការណែនាំទូទៅ រយៈពេលចិញ្ចឹមបំប៉នចំនួន ៦០ថ្ងៃ គួរត្រូវបានចាត់ទុកថាជារយៈពេលសមរម្យមួយសម្រាប់ ការចិញ្ចឹមបំប៉នគោពូជក្នុងស្រុកដែលមានសភាពស្គម ឱ្យទៅជាគោដែលមានទម្ងន់អាចពិឃាដបាន។

នៅពេលលក់គោ កសិករគួរប្រើប្រាស់នូវវិធីសាស្ត្រដូចគ្នាទៅនឹងវិធីសាស្ត្រនៅពេលទិញគោ ដូចជាការវាស់នូវតម្លៃទម្ងន់និងសាច់ដោយប្រើម៉ែត្រខ្សែ និងវាយតម្លៃនូវលក្ខខណ្ឌនិងសាច់ដុំ។ ការធ្វើរបៀបនេះ នឹងជួយឱ្យអ្នកទិញពុំសូវតថ្លៃក្នុងពេលទិញគោ។



DRAFT



*គោញីពូជក្នុងស្រុកនេះ គឺអាចពិឃាដនៅចុងអាទិត្យទី៦នៃការចិញ្ចឹមបំប៉ន។ នៅពេលគោត្រៀមសម្រាប់លក់ ប្រវែងទទឹងគោ មានទំហំធំពេញ ហើយចង្កេះ និងឆ្អឹង មិនត្រូវបាន មើលឃើញ។*

## ២.៣ ផលចំណេញផ្នែកសេដ្ឋកិច្ច

**កសិករមានជម្រើសជាច្រើនក្នុងការលក់គោ។ កសិករអាចៈ**

- មិនចិញ្ចឹមបំប៉នគោទាំងស្រុង ប៉ុន្តែរក្សាទុកគោដោយផ្តល់ចំណីតាមបែបបុរាណដល់គោរហូតដល់ពេលលក់។
- ចិញ្ចឹមបំប៉នគោដោយផ្តល់ស្មៅបៃតងដល់គោ។
- ចិញ្ចឹមបំប៉នគោដោយផ្តល់ស្មៅបៃតង និងចំណីផ្សំដល់គោ។

ក្នុងជម្រើសនីមួយៗ កសិករអាចធ្វើការលក់ដូរគោដែលពួកគេចិញ្ចឹមដោយខ្លួនឯង ឬកសិករអាចទិញគោដោយប្រើប្រាស់លុយផ្ទាល់ ឬឥណទាន។

ករណីខ្លះកសិករសំរេចចិត្តចិញ្ចឹមបំប៉នគោដោយផ្តល់ចំណីស្មៅបៃតង និងចំណីផ្សំ ហើយកសិករអាចទទួលផល ចំណេញនូវផ្នែកបច្ចេកទេសជាច្រើនដោយអាស្រ័យទៅលើប្រភេទគោដែលទិញ គុណភាពស្មៅបៃតងដែលអាចរកបាន គុណភាពចំណីផ្សំ អត្រានៃការស៊ីចំណីផ្សំ និងអត្រាកើនទម្ងន់គោជាបន្តបន្ទាប់។

**លើសពីនេះទៅទៀត វាមានការខុសគ្នានូវលទ្ធផលផ្នែកថវិកាយ៉ាងច្រើនផងដែរ ដោយសារកត្តាជាច្រើនដូចជាៈ**

- ការប្រែប្រួលនូវតម្លៃសាច់ និងសត្វគោរវាងពេលទិញ និងលក់។
- សមត្ថភាពរបស់កសិករក្នុងការវាយតម្លៃគោឱ្យបានពិតប្រាកដ។
- អំណាចរបស់អ្នកទិញ និងអ្នកលក់ក្នុងពេលទិញ និងលក់។
- ភាពខុសគ្នាក្នុងតម្លៃលក់ដូរ។
- តម្លៃ និងភាពរកបាននូវកម្មករសម្រាប់ប្រមូលស្មៅបៃតង ព្រមទាំងការគ្រប់គ្រងគោ។
- ចំណាយថវិកាលើការទិញគោប្រសិនបើត្រូវការ។
- ចំណាយលើចំណីផ្សំ។

**ការវិភាគសេដ្ឋកិច្ច ត្រូវបានបង្ហាញដោយធ្វើការប្រៀបធៀបៈ**

- កសិករមួយដែលទិញ និងចិញ្ចឹមបំប៉នគោចំនួន២ក្បាលដោយផ្តល់ចំណីស្មៅបៃតងតែមួយមុខ ការចិញ្ចឹមបែបនេះ ត្រូវបានចាត់ទុកថាជាប្រព័ន្ធចិញ្ចឹមបំប៉នគោកំរិតទាប ។
- កសិករមួយដែលទិញ និងចិញ្ចឹមបំប៉នគោចំនួន២ក្បាលដោយផ្តល់ចំណីស្មៅបៃតង និងចំណីផ្សំ ការចិញ្ចឹមបែបនេះ ត្រូវបានចាត់ទុកថាជាប្រព័ន្ធចិញ្ចឹមបំប៉នគោកំរិតខ្ពស់ ។

ក្នុងប្រព័ន្ធទាំងពីរប្រភេទ ទម្ងន់គោនៅពេលតំបូង និងចុងក្រោយមានលក្ខណៈដូចគ្នា ហើយចំណាយលើផ្នែកផ្សេងៗ មានលក្ខណៈដូចគ្នា ។ លាមកគោដែលបានមកពីប្រព័ន្ធទាំងពីរ ត្រូវបានគិតថាមានសភាពប្រហាក់ប្រហែលគ្នា ហើយចំណុចនេះ មិនត្រូវបានគិតចូលក្នុងការវិភាគសេដ្ឋកិច្ចទេ ទោះបីជាវាផ្តល់ផលចំណេញដល់កសិករក៏ដោយ ។ ការវិភាគបានបង្ហាញថា ផលចំណេញសរុបមានចំនួនប្រហាក់ប្រហែលគ្នា ប៉ុន្តែប្រព័ន្ធការចិញ្ចឹមបំប៉នកំរិតខ្ពស់ ទទួលផលចំណេញនូវពេលវេលាចំនួនពាក់កណ្តាល (៦០ថ្ងៃ)ដែលផ្ទុយនឹងប្រព័ន្ធការចិញ្ចឹមបំប៉នកំរិតទាប ដែលចំណាយពេលវេលាចំនួន ១២០ថ្ងៃ ។

តារាងទី៣. ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធការចិញ្ចឹមបំប៉នគោតាមប្រព័ន្ធការចិញ្ចឹមបំប៉នកំរិតទាបនិងខ្ពស់

| **ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធការចិញ្ចឹមបំប៉នគោតាមប្រព័ន្ធការចិញ្ចឹមបំប៉នកំរិតទាបនិងខ្ពស់** | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | **កំរិតទាប(ស្មៅបៃតងតែមួយមុខ)** | | | | **កំរិតខ្ពស់(ស្មៅបៃតងលាយចំណីផ្សំ)** | | | |
| | ឯកតា | តម្លៃរៀល / ឯកតា | ចំនួន ឯកតា | តម្លៃរៀល | ឯកតា | តម្លៃរៀល / ឯកតា | ចំនួន ឯកតា | តម្លៃរៀល |
| ចំណាយ | | | | | | | | |
| ទិញមេគោក្បាល ទី១ | គ.ក្រ | ៣៧៥០ | ២០០ | ៧៥០០០០ | គ.ក្រ | ៣៧៥០ | ២០០ | ៧៥០០០០ |
| ទិញមេគោក្បាល ទី២ | គ.ក្រ | ៣៧៥០ | ២០០ | ៧៥០០០០ | គ.ក្រ | ៣៧៥០ | ២០០ | ៧៥០០០០ |
| ថ្នាំព្យាបាល | គ.ក្រ | ២០ | ០ | ០ | គ.ក្រ | ២០ | ៤០០ | ៨០០០ |
| ស្មៅបៃតង | គ.ក្រ | ១០០ | ៥៣៤០ | ៥៣៤០០០ | គ.ក្រ | ១០០ | ១៣៣៥ | ១៣៣៥០០ |
| ចំណីផ្សំ | គ.ក្រ | ៧០០ | ០ | ០ | គ.ក្រ | ៧០០ | ៤៣៣ | ៣០២៨២០ |
| | | | | ២០៣៤០០០ | | | | ១៩៤៤៣២០ |
| ប្រាក់ចំណូល | | | | | | | | |
| ការលក់មេគោ | គ.ក្រ | ៥២៥០ | ២៤៥ | ១២៨៦២៥០ | គ.ក្រ | ៥២៥០ | ២៤៥ | ១២៨៦២៥០ |
| ការលក់គោឈ្មោល | រៀល, គ.ក្រ | ៥២៥០ | ២៤៥ | ១២៨៦២៥០ | គ.ក្រ | ៥២៥០ | ២៤៥ | ១២៨៦២៥០ |
| | | | | ២៥៧២៥០០ | | | | ២៥៧២៥០០ |
| ផលចំណេញ | | | | ៣៦៤៤១៧ | | | | ៥៩១២៩៩ |

DRAFT

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំនួនថ្ងៃពលកម្ម | ថ្ងៃ | | | ៤៥ | ថ្ងៃ | | | ២៣ |
| ប្រាក់ចំណេញ, ថ្ងៃពលកម្ម | រៀល, ថ្ងៃ | | | ១១៩៦៧ | រៀល, ថ្ងៃ | | | ២៧៩១៩ |
| ការប្រាក់លើថ្លៃដើម (៣ %ក្នុង១ខែសម្រាប់រយៈពេល ២ខែ) | | | | ១២២០៤០ | | | | ១១៦៦៥៩ |
| ប្រាក់ចំណេញដក ការប្រាក់ | | | | ៤១៦៤៦០ | | | | ៥១១៩២១ |

| ការរៀបរាប់ផ្នែកបច្ចេកទេស | | |
|---|---|---|
| ពូជគោ | ក្នុងស្រុក | |
| ភេទ | ញី | |
| អាយុ(ឆ្នាំ) | ៨ | |
| ស្ថានភាពដើម | គ្មានផ្ទៃពោះ | |
| ស្ថានភាពសុខភាព | ល្អ | |
| អារម្មណ៍ | ល្អ | |
| ការសំរបទៅនឹងចំណីផ្សំ | ការសំរបលឿន | |
| | ពេលដំបូងក្នុងរយៈពេល ការចិញ្ចឹមបំប៉ន | ពេលចុងក្រោយក្នុង រយៈពេលការចិញ្ចឹមបំប៉ន |
| លក្ខខណ្ឌ | ស្គម | ធាត់ |
| ប្រភេទសាច់ដុំ (១-៣) | ១.០ | ១.០ |
| ទម្ងន់ (គ.ក្រ) | ២០០ | ២៤៥ |
| សមាសធាតុសាច់ (%) | ២៥ | ៣៥ |
| សមាសធាតុសាច់ (គ.ក្រ) | ៥០ | ៨៥.៧៥ |
| តម្លៃសាច់ (រៀលក្នុង១គ.ក្រ) | ១៥០០០ | ១៥០០០ |
| តម្លៃសត្វគោ (រៀល) | ៧៥០០០០ | ១២៨៦២៥០ |
| | ការផ្តល់ចំណីតាម កំរិតទាប | ការផ្តល់ចំណីតាម កំរិតខ្ពស់ |
| ការកើនទម្ងន់ជាមធ្យម (គ.ក្រក្នុងថ្ងៃ) | ០.៣៨ | ០.៧៥ |
| ការកើនទម្ងន់សរុប (៤០គ.ក្រ) | ៤៥ | ៤៥ |
| ចំនួនថ្ងៃសរុប | ១២០ | ៦០ |

DRAFT

## ៣-ការណែនាំលើការខារផ្សព្វផ្សាយ

គោលការណ៍ផ្សព្វផ្សាយគឺផ្តោតទៅលើកម្មវិធីផ្សព្វផ្សាយថ្នាក់ឃុំ ។គោលការណ៍ទាំងនេះអាចតម្រូវទៅនឹងតំបន់អនុត្តដែលមានទំហំធំ (ឧទាហរណ៍ៈ ស្រុក ខេត្តប ។

### ៣.១ ការរៀបចំស្ថាប័ន

អ្នកចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយនេះមានៈ

ក- មន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាលតាមខេត្ត ។ សមាជិកនៃមន្ត្រីថ្នាក់នេះ គឺទទួលខុសត្រូវក្នុងការងារ សំរបសំរួលទូទៅនៃការផ្សព្វផ្សាយ ។

ខ- មន្ត្រីពេទ្យសត្វនៃការិយាល័យកសិកម្មស្រុក ដែលនៅក្រោមកិច្ចសន្យាក្នុងការគ្រប់គ្រងសកម្មភាពរបស់កម្មវិធី ក្នុងស្រុក ។ មន្ត្រីស្រុកធ្វើការចុះត្រួតពិនិត្យដោយផ្ទាល់ ចំពោះថ្ងៃចុះអនុវត្តនៅទីកន្លែង ។ ប្រធានការិយាល័យ កសិកម្មថ្នាក់ស្រុក នឹងមានតួនាទីគាំទ្រកម្មវិធីផងដែរ ។

គ- ភ្នាក់ងារសុខភាពសត្វភូមិ ។ ភ្នាក់ងារសុខភាពសត្វភូមិ ចូលរួមធ្វើផែនការនិងកិច្ចប្រជុំបូកសរុប នឹងចូលរួមគ្រប់ ថ្ងៃចុះអនុវត្តនៅទីកន្លែង ។ ពួកគេជួយក្នុងការជ្រើសរើសកសិករគំរូ និងកសិករដែលចូលរួម ។ ពួកគេផ្តល់ សេវាកម្មសុខភាពសត្វនៅពេលដំបូង និងក្នុងពេលចិញ្ចឹមបំប៉ន ។ភ្នាក់ងារសុខភាពសត្វភូមិមានកិច្ចសន្យាក្នុង ការផ្តល់សេវាកម្មរបស់គេ ។

ឃ- អាជ្ញាធរដែនដីនៅក្នុងភូមិ និងឃុំ ជួយនូវសកម្មភាពរបស់កម្មវិធី ។

ង- អ្នកផ្គត់ផ្គង់ចំណីផ្សំ ។

ច- អ្នកលក់ដូរគោ ដែលរួមទាំងអ្នកទិញ និងម្ចាស់កន្លែងពិឃាដសត្វ ។ អ្នកពាក់ព័ន្ធទាំងនេះ គួរត្រូវបានលើកទឹក ចិត្តឱ្យចូលរួមគ្រប់សកម្មភាពក្នុងការធ្វើបង្ហាញ ។

ឆ- កសិករគំរូត្រូវមានកិច្ចសន្យាក្នុងការគ្រប់គ្រងទីកន្លែងចិញ្ចឹមបំប៉នគោចំនួន ២ ក្បាល ។ កសិករគំរូផ្តល់គោ ២ក្បាលដែលសមស្របទៅនឹងការចិញ្ចឹមបំប៉ន ទីកន្លែងសម្រាប់ការចិញ្ចឹមបំប៉ន ស្មៅបៃតង និងពលកម្ម សម្រាប់ការគ្រប់គ្រងគោនិងទុកដាក់របាយការណ៍ ។ គំរោងផ្តល់សមាសធាតុនៃចំណីផ្សំ ជញ្ជីងដែលអាចថ្លឹង ទម្ងន់បាន ១០ត.ក្រម៉ែត្រខ្មែរ ការណែនាំបច្ចេកទេស និងឯកសារកត់ត្រាសម្រាប់ទីកន្លែងក្នុងការធ្វើបង្ហាញ និង តម្លៃសម្រាប់ទីកន្លែងក្នុងការធ្វើបង្ហាញ ដែលចំណាយលើការទិញស្នូកទឹក និងចំណីដែលបន្ថែមលើតម្លៃ ក្នុងការគ្រប់គ្រង ។ ប្រសិនបើការធ្វើបង្ហាញលើសពីចំនួន ១កន្លែងក្នុង១ឃុំ កសិករគំរូអាចធ្វើការពិនិត្យទៅ វិញទៅមក រវាងកន្លែងធ្វើបង្ហាញមួយៗ ។

ជ- កសិករចូលរួម ត្រូវចូលរួមនៅទីកន្លែងធ្វើបង្ហាញនៅគ្រប់ថ្ងៃក្នុងការធ្វើបង្ហាញ ។ ក្រុមកសិករដែលមានសមាជិក ១៥ នាក់ គួរចូលរួម៣ថ្ងៃនៅទីកន្លែងធ្វើបង្ហាញ ។ កសិករទាំងនេះអាចជាកសិករដែលមានបទពិសោធន៍ក្មេងខ្ចី ក្នុងការចិញ្ចឹមបំប៉នគោ ក៏កសិករដែលមានគោច្រើន និងមានថវិកាច្រើនក្នុងការធ្វើជំនួញចិញ្ចឹមបំប៉នគោ ។

DRAFT

## ៣.២ ការធ្វើផែនការសកម្មភាព

ផែនការសកម្មភាពមានរយៈពេលប្រហែល ៤ខែ ដែលរួមមានការធ្វើផែនការ ការអនុវត្តនូវការធ្វើបង្ហាញ និងវគ្គ ពិនិត្យ និងវាយតម្លៃ។ ចំនួនខែពិតប្រាកដនៃឆ្នាំសម្រាប់អនុវត្តគំរោង នឹងមានការប្រែប្រួលរវាងឃុំមួយទៅឃុំមួយ ដោយអាស្រ័យទៅលើភាពរកបាននៃស្មៅបៃតង និងប្រតិទិនកសិកម្មទូទៅ។ តារាងទី៤. ផែនការសកម្មភាពសម្រាប់ការផ្សព្វផ្សាយលើការចិញ្ចឹមបំប៉នគោ

| ផែនការសកម្មភាពសម្រាប់ការផ្សព្វផ្សាយលើការចិញ្ចឹមបំប៉នគោ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សកម្មភាព | ខែ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ការប្រជុំថ្នាក់ឃុំ | | | | | | | | | | | | |
| ការជ្រើសរើសទីកន្លែង | | | | | | | | | | | | |
| ការជ្រើសរើសកសិករគំរូ | | | | | | | | | | | | |
| ការហ្វឹកហ្វឺនកសិករគំរូ | | | | | | | | | | | | |
| ថ្ងៃចុះទស្សនៈកិច្ចនៅទីកន្លែងធ្វើបង្ហាញ | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកគ្រប់គ្រងថ្នាក់ស្រុក | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ខេត្ត | | | | | | | | | | | | |

DRAFT

### ការប្រជុំថ្នាក់ឃុំលើកទី១

កិច្ចប្រជុំនេះ ត្រូវបានចូលរួមដោយមន្ត្រីស្រុក និងខេត្តអាជ្ញាធរឃុំ អ្នករកស៊ីគោ និងភ្នាក់ងារសុខភាពសត្វភូមិ នៅក្នុងឃុំ។ ទិសដៅនៃកិច្ចប្រជុំនេះ គឺថាអ្នកចូលរួមយល់អំពីបច្ចេកវិទ្យា និងដំណើរការផ្សព្វផ្សាយនិងសំរេចចិត្តលើចំនួន និង ទីតាំងក្នុងការចិញ្ចឹមបំប៉នបង្ហាញ។

**ក្នុងកិច្ចប្រជុំនេះ មានៈ**

- ផ្នែកបច្ចេកទេសដែលក្នុងនោះ អ្នកចូលរួមត្រូវបានផ្តល់នូវទស្សនៈនៃផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការចិញ្ចឹមបំប៉នគោ និងស្ថានភាពបច្ចុប្បន្នក្នុងការចិញ្ចឹមបំប៉នគោ និងការលក់ដូរគោនៅក្នុងខេត្ត ស្រុក និងឃុំ។ អ្នកចូលរួមពិភាក្សាបទពិសោធន៍របស់ពួកគេដែលទាក់ទងក្នុងការចិញ្ចឹមបំប៉ន និងការលក់ដូរគោ។
- ផ្នែករៀបចំដែលពិពណ៌នាអំពីសកម្មភាពនៃកម្មវិធី។

ការជ្រើសរើសទីកន្លែងនិងកសិករគំរូ

ការជ្រើសរើសទីកន្លែង និងកសិករគំរូ គឺជាកត្តាសំខាន់ណាស់នៅក្នុងដំណើរការផ្សព្វផ្សាយ ដោយសារភាពទទួលខុសត្រូវខ្ពស់សម្រាប់កម្មវិធី គឺជាបន្ទុករបស់កសិករគំរូ។ ជាការប្រសើរបំផុត កសិករគំរូដែលនឹងជ្រើសរើសគួរមានបទពិសោធន៍ស្រាប់ក្នុងការចិញ្ចឹមបំប៉នគោ ដោយផ្តល់ស្មៅបៃតងក្នុងទិសដៅសម្រាប់លក់ដើម្បីពិឃាដ។ ប្រសិនបើកសិករបែបនេះពិបាកស្វែងរក កសិករដទៃទៀតដែលមានបំណងចិញ្ចឹមគោសម្រាប់ពិឃាដ អាចត្រូវបានជ្រើសរើស។ មន្ត្រីស្រុកត្រូវការត្រួតពិនិត្យ ទីកន្លែងដើម្បីឱ្យដឹងច្បាស់ថា ទីនោះអាចរកបាននូវស្មៅបៃតងគ្រប់គ្រាន់ ហើយត្រូវដឹងថាស្មៅដែលរកបាននោះអាចប្រមូល ឬទិញបាន ឬអត់។

មន្ត្រីស្រុកពិភាក្សាជាមួយកសិករគំរូលើកិច្ចសន្យា ហើយកសិករគំរូយល់ព្រមលើបញ្ហានេះ។ ជម្រើសចំណីផ្សំត្រូវបានពិភាក្សា និងយល់ព្រម។

ការហ្វឹកហ្វឺនកសិករគំរូ

នេះជាការហ្វឹកហ្វឺនចំនួន១ថ្ងៃសម្រាប់កសិករគំរូ និងភ្នាក់ងារសុខភាពសត្វភូមិក្នុងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ នៃការចិញ្ចឹមបំប៉នគោ និងផ្នែកគ្រប់គ្រងកម្មវិធីនៃការធ្វើបង្ហាញ។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសម្រាប់កសិករ ១៥គ្រួសារ ដើម្បីចូលរួមថ្ងៃចុះធ្វើទស្សនៈកិច្ចត្រូវបានពិភាក្សា និងយល់ព្រម។

កសិករគំរូ ភ្នាក់ងារសុខភាពសត្វភូមិ និងអាជ្ញាធរដែនដី ធ្វើការជ្រើសរើសកសិករ ១៥គ្រួសារ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានយល់ព្រម។

**ការធ្វើទស្សនៈកិច្ចថ្ងៃទី១**

នៅថ្ងៃទី១នៃការធ្វើទស្សនៈកិច្ចនេះ

- គោនិងសំភារៈផ្សេងៗ ត្រូវបានត្រួតពិនិត្យនិងពិភាក្សា។ ការវាស់ទម្ងន់គោដោយប្រើម៉ែត្រខ្សែ ត្រូវបានបង្ហាញ។ លក្ខខណ្ឌសាច់ដុំ និងទម្ងន់គោ ត្រូវបានពិភាក្សា។ តម្លៃគោ និងទីផ្សារបច្ចុប្បន្នសម្រាប់គោ និងសាច់គោត្រូវបានពិភាក្សា។
- ស្មៅបៃតងត្រូវបានត្រួតពិនិត្យសម្រាប់គុណភាពរបស់វា។
- ជម្រើសចំណីផ្សំត្រូវបានពិពណ៌នានិងចំណីផ្សំត្រូវបានលាយ។



DRAFT

- គោត្រូវបានព្យាបាលប៉ារាស៊ីត ។
- គោត្រូវបានផ្តល់ចំណីផ្សំនិងស្មៅបៃតង ។
- ការសំរបគោទៅនឹងចំណីផ្សំនឹងត្រូវបានពិភាក្សា ។
- ផែនការច្នេកទេស និងហិរញ្ញវត្ថុត្រូវបានធ្វើឡើងនិងពិភាក្សារួមទាំងការបញ្ចូលនូវចំណាយផ្សេងៗ និងពលកម្ម ។

ការធ្វើទស្សនៈកិច្ចថ្ងៃទី២

ការងារនេះគួរធ្វើឡើងប្រហែល ១ខែក្រោយ បន្ទាប់ពីការទស្សនៈកិច្ចថ្ងៃទី២ ។

- គោត្រូវបានត្រួតពិនិត្យសម្រាប់ការរីកចំរើន ហើយទម្ងន់ លក្ខខណ្ឌ កំរិតសាច់ដុំ និងតម្លៃត្រូវបានវាយតម្លៃ ។
- របាយការណ៍កសិករគំរូត្រូវបានបង្ហាញនិងពិភាក្សា ។
- កសិករគំរូ ពិភាក្សាអំពីចំនុចខ្សោយ និងខ្លាំងនៃសកម្មភាព តាំងពីពេលចាប់ផ្តើមរហូតរហូតដល់បច្ចុប្បន្ន ។
- ផែនការបច្ចេកទេស ហិរញ្ញវត្ថុ និងទីផ្សារត្រូវបានពិភាក្សា ។

ការធ្វើទស្សនៈកិច្ចថ្ងៃទី៣

ការងារនេះគួរធ្វើឡើងប្រហែល១ខែក្រោយបន្ទាប់ពីការទស្សនៈកិច្ចថ្ងៃទី១ ។

- គោត្រូវបានត្រួតពិនិត្យសម្រាប់ការរីកចំរើន ហើយទម្ងន់ លក្ខខណ្ឌ កំរិតសាច់ដុំ និងតម្លៃត្រូវបានវាយតម្លៃ ។ ជាការប្រសើរ គឺអាចអញ្ជើញអ្នកលក់ដូរគោទៅចូលរួមថ្ងៃទស្សនៈកិច្ចដើម្បីផ្តល់ជាគំនិតលើតម្លៃគោ ។
- របាយការណ៍កសិករគំរូត្រូវបានបង្ហាញ និងពិភាក្សា ។
- កសិករគំរូពិភាក្សាអំពីចំណុចខ្សោយ និងខ្លាំងនៃសកម្មភាពតាំងពីពេលចាប់ផ្តើមរហូតដល់បច្ចុប្បន្ន ។
- ជម្រើសទីផ្សារត្រូវបានពិភាក្សា ។
- លទ្ធផលបច្ចេកទេស និងហិរញ្ញវត្ថុត្រូវបានពិភាក្សា ។

ការប្រជុំថ្នាក់ឃុំលើកទី២

កិច្ចប្រជុំនេះ ត្រូវបានចូលរួមដោយមន្ត្រីស្រុក និងខេត្ត អាជ្ញាធរឃុំ អ្នកលក់ដូរគោ និងភ្នាក់ងារពេទ្យសត្វភូមិនៅក្នុងឃុំ ។ ទិសដៅនៃកិច្ចប្រជុំនេះគឺថា អ្នកចូលរួមយល់អំពីលទ្ធផលបច្ចេកទេសហិរញ្ញវត្ថុ នឹងផ្សព្វផ្សាយលើការធ្វើបង្ហាញអំពីការចិញ្ចឹមបំប៉ន ។ អ្នកចូលរួមពិភាក្សាចំណុចខ្លាំង និងខ្សោយនៃបច្ចេកវិទ្យា និងដំណើរការផ្សព្វផ្សាយ និងផ្តល់អនុសាសន៍សម្រាប់សកម្មភាពក្នុងពេលអនាគត ។

DRAFT

## ៣.៣ ឧបករណ៍ និង សំភារៈ

បញ្ជីឧបករណ៍និងសំភារៈដែលត្រូវការសម្រាប់អនុវត្ត “បទដ្ឋានអនុវត្តបច្ចេកវិទ្យា” បានបង្ហាញក្នុងតារាងខាងក្រោមៈ

**តារាងទី៥. ឧបករណ៍ និង សំភារៈ**

| |
|---|
| សៀវភៅសម្រាប់សរសេររបាយការណ៍របស់អ្នកគ្រប់គ្រងស្រុក |
| សៀវភៅសម្រាប់សរសេររបាយការណ៍របស់កសិករគំរូ |
| ការណែនាំអំពីទម្ងន់គោ |
| ការណែនាំអំពីសមាសធាតុសាច់គោពូជក្នុងស្រុក |
| ការណែនាំអំពីការផ្តល់ចំណីគោ |
| ម៉ែត្រខ្សែសម្រាប់វាស់ |
| ជញ្ជីងសម្រាប់ថ្លឹងទម្ងន់ ១០ ត.ក្រ |

គំរូសៀវភៅអ្នកគ្រប់គ្រងស្រុក របាយការណ៍កសិករគំរូការណែនាំអំពីទម្ងន់គោសមាសធាតុសាច់និងការផ្តល់ចំណីសម្រាប់ពូជគោក្នុងស្រុក ត្រូវបានណែនាំក្នុងឧបសម្ព័ន្ធ។

## ៣.៤ ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាមីអង្គភាព។ តារាងថវិកាខាងក្រោមបានបង្កើតឡើងក្នុងឆ្នាំ២០០៦ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្តបច្ចេកវិទ្យារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

**តារាងទី៦. ថវិកាសម្រាប់អនុវត្តគំរោង**

| ថវិកា និង ការសន្មត់ | ចំនួន / តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនសម្រាប់ទីកន្លែងធ្វើបង្ហាញ (ខ) | $១២៣ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ / ការណែនាំពីបច្ចេកវិទ្យា បអប | $៣០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ឃ)<br>- អាហារសំរ៉ន់ | $៩០ |
| ទុនចូលរួមពីកសិករគំរូ (ង) | កំលាំងពលកម្មគោ ២ក្បាល (១ក្បាល=២០០គីឡូ) និងធុងដាក់ចំណី |

DRAFT

| | |
|---|---|
| | |
| ទិវាស្រែ - អាហារសំរ៉ន់ (ច) | $២៥ |
| ទិវាស្រែ - សំភារៈ (ឆ) | $១០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្តុះបណ្តាល ការត្រួតពិនិត្យទីកន្លែងបង្ហាញ | $៤២ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ញ) | $២០ |
| សរុប | $៣៦៤ |

**ការសន្មត់ប្រើប្រាស់មាន**

ក. ក្នុង TIP មួយ មានក្រុមកសិករ (៣០ នាក់) និងទីកន្លែងបង្ហាញ ២កន្លែង

ខ. ទុនសម្រាប់ធ្វើបង្ហាញក្នុង ១កន្លែង ដោយមានរួមបញ្ចូលទាំងចំណីផ្សំ ៤៥០គីឡូ (១គីឡូ = ៧០០រៀល)=4៨0 ស្មៅស្រស់ ១៤០០គីឡូ (១គីឡូ=១០០រៀល)=4៤0 និងថ្នាំព្យាលបាល/វ៉ាក់សាំងការពារ=4៣ (សរុបរួម= $ ១២៣) ។ ទុនសម្រាប់ធ្វើបង្ហាញអំពីការចិញ្ចឹមគោ (សម្រាប់កាប់យកសាច់)២ក្បាល ដោយផ្តល់នូវស្មៅស្រស់ (ស៊ីតាមចិត្ត) ហើយនិងចំណីផ្សំដែលមានប្រូតេអ៊ីន រយៈពេល ៦០ថ្ងៃ ភាពធំធាត់អាចកើន បាន៧៥០ក្រាម ក្នុងមួយក្បាល/ថ្ងៃ។

គ. ឯកសារបណ្តុះបណ្តាលបច្ចេកវិទ្យា មានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀនមេរៀន ការបញ្ចាំងស្លាយ និង ផ្ទាំងរូបភាពធំៗ ដែលជាដំណើរការនៃវិធីសាស្ត្របង្រៀន។

ឃ. ការបណ្តុះបណ្តាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្តិ៍មាន តែ ២វគ្គទេ និងការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គ។

ង. ទុនចូលរួមពីកសិករមានគោ ២ក្បាល (ក្នុង១កន្លែង) ទម្ងន់ធ្ងន់ជាង ២០០គក្រ/គោ១ = ២ x $១៩០=4៣៨0 ធុងដាក់ចំណី/ស្មៅ រោងដាក់គោ និងកំលាំងពលកម្ម។

ច. ទិវាស្រែមានកន្លះថ្ងៃ មានតែម្តងក្នុងវគ្គណាមួយក្នុងចំណោមទាំងបីវគ្គ និងអាចមានការចូលរួមពីកសិករនៅ ក្បែរៗ ភូមិប្រហែល ៤០-៦០នាក់។

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមាន ឧឃោសនស័ព្ទ(មេក្រូ) តង់ និងផ្ទាំងបដារូបភាពផ្សេងៗទៀត។

ជ. ថវិកាឧបត្ថម្ភប្រចាំថ្ងៃសម្រាប់មន្ត្រីកសិកម្មស្រុក រួមមាន៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញការចាប់ ផ្តើម ការត្រួតពិនិត្យតាមដាន ចំពោះការបណ្តុះបណ្តាលសម្រាប់៣វគ្គ ផ្តល់អោយ ៦ថ្ងៃ និងទិវាស្រែផ្តល់ អោយ ២ថ្ងៃ។

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ. មន្ទីរកសិកម្មខេត្ត-អ្នកឯកទេសជំនាញផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្តុះបណ្តាល បអប

DRAFT

### ៣.៥ ទីកន្លែងអនុវត្តគម្រោង

“បទដ្ឋានអនុវត្តបច្ចេកវិទ្យា” ត្រូវបានអនុវត្តយ៉ាងជោគជ័យនៅក្នុងទីកន្លែងដែលធ្វើពិសោធន៍ក្នុងខេត្តពោធិ៍សាត់ នៅឆ្នាំ ២០០៥។ កម្មវិធីប្រហាក់ប្រហែល គ្នានេះត្រូវបានអនុវត្តយ៉ាងជោគជ័យក្នុងតំបន់កណ្តាលនៃប្រទេសវៀតណាមពីឆ្នាំ ២០០១-២០០៣។

## ៤. ឧបសម្ព័ន្ធ

### ៤.១ ឧបសម្ព័ន្ធទី១. ការណែនាំលើទម្ងន់គោ

| | | ទទឹង (ម) × ទទឹង (ម) × បណ្តោយ (ម) × ៩០ = ទម្ងន់គោ (គ.ក្រ) | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បណ្តោយ | | | | | | | | | | | | | | | |
| | | ១០១ សម | ១០២ សម | ១០៤ សម | ១០៦ សម | ១០៨ សម | ១១០ សម | ១១២ សម | ១១៤ សម | ១១៦ សម | ១១៨ សម | ១២០ សម | ១២២ សម | ១២៤ សម | ១២៦ សម | ១២៨ សម | ១៣០ សម |
| ទទឹង | ១២០ សម | ១៣០ | ១៣២ | ១៣៥ | ១៣៧ | ១៤០ | ១៤៣ | ១៤៥ | ១៤៨ | ១៥០ | ១៥៣ | ១៥៦ | ១៥៨ | ១៦១ | ១៦៣ | ១៦៦ | ១៦៨ |
| | ១២២ សម | ១៣៤ | ១៣៧ | ១៣៩ | ១៤២ | ១៤៥ | ១៤៧ | ១៥០ | ១៥៣ | ១៥៥ | ១៥៨ | ១៦១ | ១៦៣ | ១៦៦ | ១៦៩ | ១៧១ | ១៧៤ |
| | ១២៤ សម | ១៣៨ | ១៤១ | ១៤៤ | ១៤៧ | ១៤៩ | ១៥២ | ១៥៥ | ១៥៨ | ១៦១ | ១៦៣ | ១៦៦ | ១៦៩ | ១៧២ | ១៧៤ | ១៧៧ | ១៨០ |
| | ១២៦ សម | ១៤៣ | ១៤៦ | ១៤៩ | ១៥១ | ១៥៤ | ១៥៧ | ១៦០ | ១៦៣ | ១៦៦ | ១៦៩ | ១៧១ | ១៧៤ | ១៧៧ | ១៨០ | ១៨៣ | ១៨៦ |
| | ១២៨ សម | ១៤៧ | ១៥០ | ១៥៣ | ១៥៦ | ១៥៩ | ១៦២ | ១៦៥ | ១៦៨ | ១៧១ | ១៧៤ | ១៧៧ | ១៨០ | ១៨៣ | ១៨៦ | ១៨៩ | ១៩២ |
| | ១៣០ សម | ១៥២ | ១៥៥ | ១៥៨ | ១៦១ | ១៦៤ | ១៦៧ | ១៧០ | ១៧៣ | ១៧៦ | ១៧៩ | ១៨៣ | ១៨៦ | ១៨៩ | ១៩២ | ១៩៥ | ១៩៨ |
| | ១៣២មម | ១៥៧ | ១៦០ | ១៦៣ | ១៦៦ | ១៦៩ | ១៧២ | ១៧៦ | ១៧៩ | ១៨២ | ១៨៥ | ១៨៨ | ១៩១ | ១៩៤ | ១៩៨ | ២០១ | ២០៤ |
| | ១៣៤ សម | ១៦២ | ១៦៥ | ១៦៨ | ១៧១ | ១៧៥ | ១៧៨ | ១៨១ | ១៨៤ | ១៨៧ | ១៩១ | ១៩៤ | ១៩៧ | ២០០ | ២០៤ | ២០៧ | ២១០ |
| | ១៣៦សម | ១៦៦ | ១៧០ | ១៧៣ | ១៧៦ | ១៨០ | ១៨៣ | ១៨៦ | ១៩០ | ១៩៣ | ១៩៦ | ២០០ | ២០៣ | ២០៦ | ២១០ | ២១៣ | ២១៦ |
| | ១៣៨សម | ១៧១ | ១៧៥ | ១៧៨ | ១៨២ | ១៨៥ | ១៨៩ | ១៩២ | ១៩៥ | ១៩៩ | ២០២ | ២០៦ | ២០៩ | ២១៣ | ២១៦ | ២១៩ | ២២៣ |
| | ១៤០ សម | ១៧៦ | ១៨០ | ១៨៣ | ១៨៧ | ១៩១ | ១៩៤ | ១៩៨ | ២០១ | ២០៥ | ២០៨ | ២១២ | ២១៥ | ២១៩ | ២២២ | ២២៦ | ២២៩ |
| | ១៤២ សម | ១៨១ | ១៨៥ | ១៨៩ | ១៩២ | ១៩៦ | ២០០ | ២០៣ | ២០៧ | ២១១ | ២១៤ | ២១៨ | ២២១ | ២២៥ | ២២៩ | ២៣២ | ២៣៦ |
| | ១៤៤ សម | ១៨៧ | ១៩០ | ១៩៤ | ១៩៨ | ២០២ | ២០៥ | ២០៩ | ២១៣ | ២១៦ | ២២០ | ២២៤ | ២២៨ | ២៣១ | ២៣៥ | ២៣៩ | ២៤៣ |
| | ១៤៦ សម | ១៩២ | ១៩៦ | ២០០ | ២០៣ | ២០៧ | ២១១ | ២១៥ | ២១៩ | ២២៣ | ២២៦ | ២៣០ | ២៣៤ | ២៣៨ | ២៤២ | ២៤៦ | ២៤៩ |
| | ១៤៨ សម | ១៩៧ | ២០១ | ២០៥ | ២០៩ | ២១៣ | ២១៧ | ២២១ | ២២៥ | ២២៩ | ២៣៣ | ២៣៧ | ២៤១ | ២៤៤ | ២៤៨ | ២៥២ | ២៥៦ |
| | ១៥០ សម | ២០៣ | ២០៧ | ២១១ | ២១៥ | ២១៩ | ២២៣ | ២២៧ | ២៣១ | ២៣៥ | ២៣៩ | ២៤៣ | ២៤៧ | ២៥១ | ២៥៥ | ២៥៩ | ២៦៣ |
| | ១៥២ សម | ២០៨ | ២១២ | ២១៦ | ២២០ | ២២៥ | ២២៩ | ២៣៣ | ២៣៧ | ២៤១ | ២៤៥ | ២៥០ | ២៥៤ | ២៥៨ | ២៦២ | ២៦៦ | ២៧០ |
| | ១៥៤ សម | ២១៣ | ២១៨ | ២២២ | ២២៦ | ២៣១ | ២៣៥ | ២៣៩ | ២៤៣ | ២៤៨ | ២៥២ | ២៥៦ | ២៦០ | ២៦៥ | ២៦៩ | ២៧៣ | ២៧៧ |
| | ១៥៦ សម | ២១៩ | ២២៣ | ២២៨ | ២៣២ | ២៣៧ | ២៤១ | ២៤៥ | ២៥០ | ២៥៤ | ២៥៨ | ២៦៣ | ២៦៧ | ២៧២ | ២៧៦ | ២៨០ | ២៨៥ |
| | ១៥៨ សម | ២២៥ | ២២៩ | ២៣៤ | ២៣៨ | ២៤៣ | ២៤៧ | ២៥២ | ២៥៦ | ២៦១ | ២៦៥ | ២៧០ | ២៧៤ | ២៧៩ | ២៨៣ | ២៨៨ | ២៩២ |
| | ១៦០ សម | ២៣០ | ២៣៥ | ២៤០ | ២៤៤ | ២៤៩ | ២៥៣ | ២៥៨ | ២៦៣ | ២៦៧ | ២៧២ | ២៧៦ | ២៨១ | ២៨៦ | ២៩០ | ២៩៥ | ៣០០ |
| | ១៦២ សម | ២៣៦ | ២៤១ | ២៤៦ | ២៥០ | ២៥៥ | ២៦០ | ២៦៥ | ២៦៩ | ២៧៤ | ២៧៩ | ២៨៣ | ២៨៨ | ២៩៣ | ២៩៨ | ៣០២ | ៣០៧ |
| | ១៦៤ សម | ២៤២ | ២៤៧ | ២៥២ | ២៥៧ | ២៦១ | ២៦៦ | ២៧១ | ២៧៦ | ២៨១ | ២៨៦ | ២៩០ | ២៩៥ | ៣០០ | ៣០៥ | ៣១០ | ៣១៥ |
| | ១៦៦ សម | ២៤៨ | ២៥៣ | ២៥៨ | ២៦៣ | ២៦៨ | ២៧៣ | ២៧៨ | ២៨៣ | ២៨៨ | ២៩៣ | ២៩៨ | ៣០៣ | ៣០៨ | ៣១២ | ៣១៧ | ៣២២ |

## ៤.២ ឧបសម្ព័ន្ធទី២. ការណែនាំលើការផ្តល់ចំណីគោ

| ការណែនាំលើការផ្តល់ចំណីគោនិងការកើនទម្ងន់គោ | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទម្ងន់គោដំបូង | ការផ្តល់ចំណីផ្សំដល់គោ (គ.ក្រ ក្បា ថ្ងៃ) | | | | | | | | ចំនួនសរុបនៃចំណីផ្សំ (គ.ក្រ) | | ការកើនទម្ងន់ដែលចង់បាន (គក្រ) | | ទម្ងន់ចុងក្រោយដែល ចង់បាន (គក្រ) | |
| | អាទិត្យ ១ | អាទិត្យ ២ | អាទិត្យ៣ | អាទិត្យ ៤ | អាទិត្យ ៥ | អាទិត្យ ៦ | អាទិត្យ ៧ | អាទិត្យ ៨ | | | | | | |
| ១៥០ គក្រ | ២.៦ | ២.៧ | ២.៨ | ៣.០ | ៣.១ | ៣.២ | ៣.៣ | ៣.៥ | = | ១៦០ គក្រ | ➡ | | ➡ | ១៨៥-១៩៥ |
| ១៦០ គក្រ | ២.៧ | ២.៩ | ៣.០ | ៣.១ | ៣.៣ | ៣.៤ | ៣.៥ | ៣.៧ | = | ១៦៩ គក្រ | ➡ | | ➡ | ១៩៥-២០៥ |
| ១៧០ គក្រ | ២.៩ | ៣.០ | ៣.២ | ៣.៣ | ៣.៤ | ៣.៦ | ៣.៧ | ៣.៩ | = | ១៧៨ គក្រ | ➡ | ៣៥-៤៥ | ➡ | ២០៥-២១៥ |
| ១៨០ គក្រ | ៣.១ | ៣.២ | ៣.៣ | ៣.៥ | ៣.៦ | ៣.៧ | ៣.៩ | ៤.០ | = | ១៨៧ គក្រ | ➡ | | ➡ | ២១៥-២២៥ |
| ១៩០ គក្រ | ៣.២ | ៣.៤ | ៣.៥ | ៣.៦ | ៣.៨ | ៣.៩ | ៤.១ | ៤.២ | = | ១៩៧ គក្រ | ➡ | | ➡ | ២២៥-២៣៥ |
| ២០០ គក្រ | ៣.៤ | ៣.៦ | ៣.៨ | ៤.០ | ៤.២ | ៤.៤ | ៤.៦ | ៤.៦ | = | ២១៦ គក្រ | ➡ | | ➡ | ២៤៥-២៥៥ |
| ២១០ គក្រ | ៣.៦ | ៣.៨ | ៤.០ | ៤.២ | ៤.៤ | ៤.៦ | ៤.៨ | ៤.៨ | = | ២២៥ គក្រ | ➡ | | ➡ | ២៥៥-២៦៥ |
| ២២០ គក្រ | ៣.៧ | ៣.៩ | ៤.១ | ៤.៣ | ៤.៥ | ៤.៧ | ៤.៩ | ៥.០ | = | ២៣៥ គក្រ | ➡ | ៤៥-៥៥ | ➡ | ២៦៥-២៧៥ |
| ២៣០ គក្រ | ៣.៩ | ៤.១ | ៤.៣ | ៤។៥ | ៤.៧ | ៤.៩ | ៥.២ | ៥.២ | = | ២៤៤ គក្រ | ➡ | | ➡ | ២៧៥-២៨៥ |
| ២៤០ គក្រ | ៤.១ | ៤.៣ | ៤.៥ | ៤.៧ | ៤.៩ | ៥.១ | ៥.៣ | ៥.៥ | = | ២៥៤ គក្រ | ➡ | | ➡ | ២៨៥-២៩៥ |
| ២៥០ គក្រ | ៤.៣ | ៤.៦ | ៤.៨ | ៥.១ | ៥.៣ | ៥.៦ | ៥.៨ | ៥.៧ | = | ២៧៣ គក្រ | ➡ | | ➡ | ៣០៥-៣១៥ |
| ២៦០ គក្រ | ៤.៤ | ៤.៧ | ៤.៩ | ៥.២ | ៥.៤ | ៥.៨ | ៦.០ | ៦.០ | = | ២៨២ គក្រ | ➡ | | ➡ | ៣១៥-៣២៥ |
| ២៧០ គក្រ | ៤.៦ | ៤.៩ | ៥.១ | ៥.៤ | ៥.៦ | ៥.៩ | ៦.១ | ៦.៣ | = | ២៩១ គក្រ | ➡ | ៥៥-៦៥ | ➡ | ៣២៥-៣៣៥ |
| ២៨០ គក្រ | ៤.៨ | ៥.១ | ៥.៣ | ៥.៦ | ៥.៨ | ៦.១ | ៦.៣ | ៦.៤ | = | ៣០១ គក្រ | ➡ | | ➡ | ៣៣៥-៣៤៥ |
| ២៩០ គក្រ | ៤.៩ | ៥.៣ | ៥.៥ | ៥.៨ | ៦.០ | ៦.៣ | ៦.៥ | ៦.៥ | = | ៣១១ គក្រ | ➡ | | ➡ | ៣៤៥-៣៥៥ |
| ៣០០ គក្រ | ៥.១ | ៥.៤ | ៥.៦ | ៥.៩ | ៦.១ | ៦.៥ | ៦.៧ | ៦.៨ | = | ៣១៩ គក្រ | ➡ | | ➡ | ៣៥៥-៣៦៥ |

<u>សំគាល់:</u> ក្នុងរយះពេលអាទិត្យទី១ក្នុងការផ្តល់ចំណី ចំណីផ្សំគួរត្រូវបានផ្តល់បន្តិចម្តងៗក្នុងទិសដៅឱ្យចំណីស្ថិតក្នុងកំរិតមួយដែលសមស្របទៅនឹងរយះពេលចុងអាទិត្យ ទី១

DRAFT

## ៤.៣ ឧបសម្ព័ន្ធទី៣. ការណែនាំលើសមាសធាតុសាច់នៃគោក្នុងស្រុក

### គំរូនៃពិន្ទុលក្ខខណ្ឌនិងសមាសធាតុសាច់នៃគោពូជក្នុងស្រុក



| | |
|---|---|
| ពូជ | ក្នុងស្រុក |
| ភេទ | ញី |
| អាយុ | ពេញវ័យ |
| ប្រភេទសាច់ដុំ | ១ |
| ពិន្ទុលក្ខខណ្ឌ | ខ្លាញ់ |
| សមាសធាតុសាច់ | ៣២ % |



| | |
|---|---|
| ពូជ | ក្នុងស្រុក |
| ភេទ | ឈ្មោល (ក្រៀវ) |
| អាយុ | ពេញវ័យ |
| ប្រភេទសាច់ដុំ | ១ |
| ពិន្ទុលក្ខខណ្ឌ | មធ្យម |
| សមាសធាតុសាច់ | ២៧% |



| | |
|---|---|
| ពូជ | ក្នុងស្រុក |
| ភេទ | ឈ្មោល (ក្រៀវ) |
| អាយុ | ពេញវ័យ |
| ប្រភេទសាច់ដុំ | ១ |
| ពិន្ទុលក្ខខណ្ឌ | មធ្យម |
| សមាសធាតុសាច់ | ២៧% |

DRAFT

## ៤.៤ ឧបសម្ព័ន្ធទី៤. របាយការណ៍របស់កសិករគំរូ

| ការចិញ្ចឹមបំប៉នគោ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| របាយការណ៍របស់កសិករគំរូ | | | | | | | | |
| របាយការណ៍ប្រចាំថ្ងៃនៃការចិញ្ចឹមបំប៉នគោ | | | | | | | | |
| អាទិត្យនិងថ្ងៃ | | កាលបរិច្ឆេទ | គោទី១ | | | គោទី២ | | |
| | | | ចំណីផ្សំ (គក្រ) | ចំណីស្មៅ (គក្រ) | ថ្នាំ | ចំណីផ្សំ (គក្រ) | ចំណីស្មៅ (គក្រ) | ថ្នាំ |
| ១ | ១ | | | | | | | |
| | ២ | | | | | | | |
| | ៣ | | | | | | | |
| | ៤ | | | | | | | |
| | ៥ | | | | | | | |
| | ៦ | | | | | | | |
| | ៧ | | | | | | | |
| ២ | ៨ | | | | | | | |
| | ៩ | | | | | | | |
| | ១០ | | | | | | | |
| | ១១ | | | | | | | |
| | ១២ | | | | | | | |
| | ១៣ | | | | | | | |
| | ១៤ | | | | | | | |
| ៣ | ១៥ | | | | | | | |
| | ១៦ | | | | | | | |
| | ១៧ | | | | | | | |
| | ១៨ | | | | | | | |
| | ១៩ | | | | | | | |
| | ២០ | | | | | | | |

DRAFT

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ២១ | | | | | | | |
| | ២២ | | | | | | | |
| | ២៣ | | | | | | | |
| | ២៤ | | | | | | | |
| ៤ | ២៥ | | | | | | | |
| | ២៦ | | | | | | | |
| | ២៧ | | | | | | | |
| | ២៨ | | | | | | | |
| | ២៩ | | | | | | | |
| | ៣០ | | | | | | | |
| | ៣១ | | | | | | | |
| ៥ | ៣២ | | | | | | | |
| | ៣៣ | | | | | | | |
| | ៣៤ | | | | | | | |
| | ៣៥ | | | | | | | |
| | ៣៦ | | | | | | | |
| | ៣៧ | | | | | | | |
| | ៣៨ | | | | | | | |
| ៦ | ៣៩ | | | | | | | |
| | ៤០ | | | | | | | |
| | ៤១ | | | | | | | |
| | ៤២ | | | | | | | |
| | ៤៣ | | | | | | | |
| | ៤៤ | | | | | | | |
| | ៤៥ | | | | | | | |
| ៧ | ៤៦ | | | | | | | |
| | ៤៧ | | | | | | | |
| | ៤៨ | | | | | | | |

DRAFT

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ៤៩ | | | | | | | |
| ៨ | ៥០ | | | | | | | |
| | ៥១ | | | | | | | |
| | ៥២ | | | | | | | |
| | ៥៣ | | | | | | | |
| | ៥៤ | | | | | | | |
| | ៥៥ | | | | | | | |
| | ៥៦ | | | | | | | |
| ៩ | ៥៧ | | | | | | | |
| | ៥៨ | | | | | | | |
| | ៥៩ | | | | | | | |
| | ៦០ | | | | | | | |
| | ៦១ | | | | | | | |
| | ៦២ | | | | | | | |
| | ៦៣ | | | | | | | |

| ការចិញ្ចឹមបំប៉នគោ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| របាយការណ៍កសិករគំរូ | | | | | | | | | | | |
| ការត្រួតពិនិត្យគោ | | | | | | | | | | | |
| | | គោទី១ | | | | | គោទី២ | | | | |
| អាយុ | | | | | | | | | | | |
| ភេទ | | | | | | | | | | | |
| ពូជ | | | | | | | | | | | |
| លក្ខខណ្ឌ | | | | | | | | | | | |
| ថ្ងៃ | កាលបរិច្ឆេទ | ទទឹង | បណ្ដោ<br>យ | ទម្ងន់<br>(គក្រ) | សាច់<br>(%) | តម្លៃ<br>(រៀល) | ទទឹង | បណ្ដោ<br>យ | ទម្ងន់<br>(គក្រ) | សាច់<br>(%) | តម្លៃ<br>(រៀល |
| 0 | | | | | | | | | | | |

DRAFT

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៥ | | | | | | | | | | | |
| ១២ | | | | | | | | | | | |
| ១៩ | | | | | | | | | | | |
| ២៦ | | | | | | | | | | | |
| ៣៣ | | | | | | | | | | | |
| ៤០ | | | | | | | | | | | |
| ៤៧ | | | | | | | | | | | |
| ៥៤ | | | | | | | | | | | |
| ៦១ | | | | | | | | | | | |

## ៤.៥ ឧបសម្ព័ន្ធទី៥ សៀវភៅគំរូអ្នកគ្រប់គ្រងថ្នាក់ស្រុក

| សៀវភៅគំរូអ្នកគ្រប់គ្រងថ្នាក់ស្រុក | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | គោទី១ | | | | គោទី២ | | | |
| | ឯកតា | តម្លៃរៀល / ឯកតា | ចំនួន ឯកតា | តម្លៃ (រៀល) | ឯកតា | តម្លៃរៀល / ឯកតា | ចំនួន ឯកតា | តម្លៃ (រៀល) |
| ចំណាយ | | | | | | | | |
| ទិញគោ | គ.ក្រ | | | | គ.ក្រ | | | |
| ថ្នាំព្យាបាល | គ.ក្រ | | | | គ.ក្រ | | | |
| ស្មៅបៃតង | គ.ក្រ | | | | គ.ក្រ | | | |
| ចំណីផ្សំ | គ.ក្រ | | | | គ.ក្រ | | | |
| | | | | | | | | |
| ប្រាក់ចំណូល | | | | | | | | |
| ការលក់គោ | គ.ក្រ | | | | គ.ក្រ | | | |

DRAFT

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| ផលចំណេញ | | | | | | | | |
| ថ្ងៃផ្តល់ចំណីសរុប | | | | | | | | |
| ចំនួនថ្ងៃពលកម្ម | ថ្ងៃ | | | | ថ្ងៃ | | | |
| ប្រាក់ចំណេញ, ថ្ងៃពលកម្ម | រៀល, ថ្ងៃ | | | | រៀល, ថ្ងៃ | | | |

| សៀវភៅអ្នកគ្រប់គ្រងថ្នាក់ស្រុក | | | | |
|---|---|---|---|---|
| ចំណីផ្សំ | | | | |
| ១ | សមាសធាតុផ្សំ | ចំនួន (គក្រ) | តម្លៃ (រៀលក្នុង គក្រ) | តម្លៃ (រៀល) |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| | សរុប | | | |

| ការរៀបរាប់ផ្នែកបច្ចេកទេសសម្រាប់គោទី១ | | |
|---|---|---|
| ពូជគោ | | |
| ភេទ | | |
| អាយុ(ឆ្នាំ) | | |
| ស្ថានភាពដើម | | |
| ស្ថានភាពសុខភាព | | |
| អារម្មណ៍ | | |
| ការសំរបទៅនឹងចំណីផ្សំ | | |
| | ពេលដំបូងក្នុងរយៈពេលការចិញ្ចឹមបំប៉ន | ពេលចុងក្រោយក្នុងរយៈពេលការចិញ្ចឹមបំប៉ន |
| លក្ខខណ្ឌ | | |
| ប្រភេទសាច់ដុំ (១-៣) | | |
| ទម្ងន់ (គ.ក្រ) | | |
| សមាសធាតុសាច់ (%) | | |
| សមាសធាតុសាច់ (គ.ក្រ) | | |

DRAFT

| | | |
|---|---|---|
| តម្លៃសាច់ (រៀលក្នុង១គ.ក្រ) | | |
| តម្លៃសត្វគោ (រៀល) | | |
| ការកើនទម្ងន់ជាមធ្យម(គ.ក្រក្នុងថ្ងៃ) | | |
| ការកើនទម្ងន់សរុប (៤0គ.ក្រ) | 0 | |
| ចំនួនថ្ងៃសរុប | ១២0 | |

| ការរៀបរាប់ផ្នែកបច្ចេកទេសសម្រាប់គោទី២ | | |
|---|---|---|
| ពូជគោ | | |
| ភេទ | | |
| អាយុ(ឆ្នាំ) | | |
| ស្ថានភាពដើម | | |
| ស្ថានភាពសុខភាព | | |
| អារម្មណ៍ | | |
| ការសំរបទៅនឹងចំណីថ្មី | | |
| | ពេលដំបូងក្នុងរយៈពេលការចិញ្ចឹមបំប៉ន | ពេលចុងក្រោយក្នុងរយៈពេលការចិញ្ចឹមបំប៉ន |
| លក្ខខណ្ឌ | | |
| ប្រភេទសាច់ដុំ (១-៣) | | |
| ទម្ងន់ (គ.ក្រ) | | |
| សមាសធាតុសាច់ (%) | | |
| សមាសធាតុសាច់ (គ.ក្រ) | | |
| តម្លៃសាច់ (រៀលក្នុង១គ.ក្រ) | | |
| តម្លៃសត្វគោ (រៀល) | | |
| ការកើនទម្ងន់ជាមធ្យម (គ.ក្រក្នុងថ្ងៃ) | | |
| ការកើនទម្ងន់សរុប (៤0គ.ក្រ) | 0 | |
| ចំនួនថ្ងៃសរុប | ១២0 | |

DRAFT